# ប្រជុំគោលធម៌
# សមថ វិបស្សនា

រៀបរៀងដោយ
**ភិក្ខុ ឌិន តេន ឥន្ទប្បញ្ញោ**

បោះពុម្ពចែកជាធម្មទាន
លើកទី ២ ចំនួន ៥០០ ក្បាល

ដោយពុទ្ធបរិស័ទ វត្តពោធិវង្ស
ប្រទេសបារាំង

**ព.ស. ២៥៦៣ គ.ស. ២០២០**

# អារម្ភកថា

ខ្ញុំសង្កេតឃើញ មានអ្នកបដិបត្តិធម៌ច្រើនគ្នា ដែលមិនចេះមិនចាំគោលធម៌ ។ អ្នកមិនចេះ មិនចាំគោលធម៌ ក៏អាចបដិបត្តិធម៌បានសម្រេចប្រយោជន៍ បានសម្រេចមគ្គផលដែរ ប៉ុន្តែ បើគេចេះ គេចាំគោលធម៌ខ្លះផង វាជាការល្អ សំរាប់គេ និងសំរាប់ជួយអ្នកឯទៀតផង ។

ដើម្បីជួយឱ្យងាយស្រួលក្នុងការចេះចាំគោលធម៌ ទើបខ្ញុំសរសេរគោលធម៌ខ្លី ៗ ដាក់ឈ្មោះថា ឧបករណ៍ សមថ វិបស្សនា ហើយចាត់ការបោះពុម្ពកូនសៀវភៅនេះឡើង ។

ខ្ញុំសង្ឃឹមថា កូនសៀវភៅនេះ នឹងបានជាប្រយោជន៍ ដល់លោក អ្នកបដិបត្តិធម៌ និង លោក អ្នកអានខ្លះ ជាពុំខាន ។

វត្តពោធិវង្ស ថ្ងៃ១៤ មេសា ព.ស. ២៥៤៦

**ភិក្ខុ ខិន គេន ឥន្ទប្បញ្ញោ**

# អារម្ភកថាទីពីរ

ក្នុងការបោះពុម្ពលើកទីមួយ ដោយតម្រូវការប្រញាប់ពេក ខ្ញុំមិនបានមើល មិនបានពិនិត្យ ឱ្យសព្វគ្រប់បានដាក់ឈ្មោះកូនសៀវភៅនោះថា ឧបករណ៍ សមថ វិបស្សនា ។ ថ្ងៃក្រោយមកខ្ញុំបានដឹងថា មានសៀវភៅគេបោះពុម្ពមុន ឈ្មោះថា ឧបករណ៍ សមថ វិបស្សនា រួចទៅហើយ ។

ការបោះពុម្ពលើកទីពីរនេះ ខ្ញុំបម្រុងនឹងដាក់ឈ្មោះថា ដៃគូសមថ វិបស្សនា ប៉ុន្តែ អ្នករៀបចំការ បានដាក់ឈ្មោះថា ប្រជុំគោលធម៌ សមថ វិបស្សនា ដូច្នេះវិញ នេះជាការសមរម្យហើយ ។

អាស្រ័យហេតុនេះ សៀវភៅឧបករណ៍ សមថ វិបស្សនា មិនអនុញ្ញាតឱ្យបោះពុម្ពទៀតទេ ។ សូមលោកអ្នក សិក្សាតាមសៀវភៅប្រជុំគោលធម៌ សមថ វិបស្សនានេះចុះ ព្រោះខ្ញុំបានពិនិត្យ កែសម្រួល និង បន្ថែមគោលធម៌ល្អជាងមុន ។

វត្តពោធិវង្ស ថ្ងៃ២០ ខែធ្នូ ២០១៩

**ភិក្ខុ ខិន គេន ឥន្ទប្បញ្ញោ**

# ចតុរារក្ខភាវនា

**នមាមិ ពុទ្ធំ គុណសាគរន្តំ**
**សត្តា សទា ហោន្តុ សុខី អវេរា**
**កាយោ ជិគុច្ឆោ សកលោ ទុគន្ធោ**
**គច្ឆន្តិ សព្វេ មរណំ តថាហំ ។**

ខ្ញុំបង្គំព្រះពុទ្ធ          គុណធំផុតដូចសាគរ
ញ៉ាំងសត្វឱ្យចេញចរ    ចាកសង្សារភពនានា ។
ពួកសត្វនៅសព្វឋាន    សូមកុំមានពៀរវេរា
ចេះថែរក្សាគ្នា          រាល់វេលាទាំងយប់ថ្ងៃ ។
កាយទាំងមូលនេះណា   មានក្លិនអាក្រក់ពេកក្រៃ
គួរខ្ពើមគ្មានថ្លាថ្លៃ    ចូរកែខៃរកធម៌ឆាប់ ។
គ្រប់សត្វនៅសព្វឋាន  ជៀសមិនបានពីក្ដីស្លាប់
ខ្លួនអញមិនយូរឆាប់    គង់តែស្លាប់ដូចគេដែរ ។

កំណាព្យធម៌នេះ ដកស្រង់ចេញពីភូមាកម្មដ្ឋានកថា ដោយ **ព្រះធម្មិស្សរោ ឯក ញឹក** ។
រោងពុម្ពខេមរជាតិ ភ្នំពេញ ១៩៥៤ ទំព័រ ១ - ២ ។

# ប្រជុំគោលធម៌ សមថ វិបស្សនា

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

## ធម៌ពួក ១

**អប្បមាទ** សេចក្តីមិនប្រមាទ ការមិនប្រហែសធ្វេសជាឫសគល់ ជាទីប្រជុំចុះ នៃធម៌ជាកុសលទាំងឡាយ ។

**យោនិសោមនសិការ** ការគិតរាវរកឫសគល់ (ហេតុ) ការគិតម៉ត់ចត់ដោយឧបាយនៃបញ្ញា ការគិតត្រូវទំនង ជាបុព្វនិមិត្តនៃអដ្ឋង្គិកមគ្គ។

## ធម៌ពួក ២

### ធម៌ដែលត្រូវចំរើន ២ យ៉ាង

១. **សមថ** សេចក្តីស្ងប់ ការអប់រំចិត្តឱ្យស្ងប់

២. **វិបស្សនា** បញ្ញាឃើញច្បាស់ ការអប់រំចិត្តឱ្យកើតបញ្ញាឃើញច្បាស់ ។

ត្រូវចំរើន គឺត្រូវបដិបត្តិ ។ សេចក្តីស្ងប់ សំដៅយកសេចក្តី

ស្ងប់កិលេស គ្រឿងសៅហ្មងចិត្ត គឺនីវរណធម៌ ។ ឃើញច្បាស់ មិនមែនភ្នែកឃើញច្បាស់ទេ គឺបញ្ញាឃើញច្បាស់តាមសេចក្ដីពិត ។ ការបដិបត្តិ លោកហៅថា ភាវនា ។ បដិបត្តិដើម្បីឱ្យចិត្តស្ងប់ ហៅថា សមថភាវនា បដិបត្តិដើម្បីឱ្យចិត្តកើតបញ្ញាឃើញច្បាស់ ហៅថាវិបស្សនាភាវនា ។

## ធម៌មានឧបការៈច្រើន ២ យ៉ាង

**១.សតិ** សេចក្ដីនឹករឭក ការប្រុងប្រយ័ត្ន

**២. សម្បជញ្ញៈ** សេចក្ដីដឹងខ្លួន ។

ធម៌ ២ យ៉ាងនេះ មានប្រយោជន៍ច្រើនណាស់ ត្រូវប្រើគ្រប់កិច្ចការទាំងអស់ ទាំងផ្លូវលោក ទាំងផ្លូវធម៌ ។ បើខ្វះធម៌ ២ យ៉ាងនេះ ធ្វើអ្វីក៏មិនសម្រេចផលប្រយោជន៍ល្អដែរ ។

## ធម៌ដែលត្រូវកំណត់ដឹង ២ យ៉ាង

**១. រូប**

**២. នាម**

រូប គឺ មហាភូតរូប ៤ និង ឧបាទាយរូប ២៤ ។ រូប គឺ ធាតុមិនដឹងរបស់ណាវិនាសដោយក្ដៅ ត្រជាក់ គំលាន សម្រេក សម្ពស្សនៃរបោមមូស ខ្យល់ កំដៅថ្ងៃ ពស់តូច ពស់ធំ របស់នោះហៅថា

រូប។នាម គឺ វេទនា  សញ្ញា  សង្ខារ  វិញ្ញាណ។នាម គឺធាតុដឹង ។ រូបនាម កើតឡើងហើយ  ប្រែប្រួលរលត់ទៅជាធម្មតា។ ត្រូវកំណត់ដឹង គឺ  ត្រូវស្គាល់វាឱ្យច្បាស់  វាកើតយ៉ាងម៉េច ? រលត់យ៉ាងម៉េច ? មានគុណ   មានទោសយ៉ាងម៉េច ?   គេអាចរលាស់វាចោលបានឬទេ ? ។ល។

## សង្ខារ ២ យ៉ាង

**១. ឧបាទិន្នកសង្ខារ**  សង្ខារមានចិត្ត មានវិញ្ញាណ

ឧ.មនុស្ស សត្វ ជាដើម ។

**២.អនុប្បាទិន្នកសង្ខារ**  សង្ខារមិនមានចិត្ត មិនមាន វិញ្ញាណ

ឧ. ផ្ទះ របស់ប្រើប្រាស់ផ្សេងៗ ជាដើម ។

សង្ខារគឺអ្វីដែលបច្ច័យប្រជុំតាក់តែង   បានសេចក្តីថា   រួមផ្សំគ្នាទើបអាចកើតឡើងបាន ។ អ្វីទាំងអស់ក្នុងលោក មិនមែនធាតុទោលតែមួយទេ សូម្បីក្នុងទឹក ១ ដំណក់ ក្នុងថ្ម ១ ដុំ ក៏សុទ្ធតែរួមផ្សំគ្នាទើបអាចកើតឡើងបាន នេះជា **សង្ខារ** ។ ឯព្រះនិព្វាន មិនមាន បច្ច័យតាក់តែងទេជា **វិសង្ខារ** ។

## ធម៌ ២ យ៉ាង

**១. សង្ខតធម៌**  ធម៌ដែលមានបច្ច័យប្រជុំតាក់តែង ។

**២. អសង្ខតធម៌** ធម៌ដែលមិនមានបច្ច័យប្រជុំតាក់តែង ។ សង្ខត

ធម៌ ត្រូវនៅក្រោមច្បាប់ព្រះត្រៃលក្ខណ៍ ឯអសង្ខតធម៌ គឺ ព្រះនិព្វាន មិននៅក្រោមច្បាប់ព្រះត្រៃលក្ខណ៍ទេ ប៉ុន្តែ ព្រះនិព្វាន ជាអនត្តាដែរ។

## ឈាន ២ យ៉ាង

**១. រូបឈាន**

**២. អរូបឈាន**

ការសម្លឹងអារម្មណ៍ ដោយចិត្តជា អប្បនាសមាធិ ហៅថា ឈាន ។ ការដុតកម្ដៅកិលេសឱ្យក្រៀម ហៅថា ឈាន ។

រូបឈាន ឈានមានរូបធម៌ជាអារម្មណ៍, ឈានជា អរូបាវចរ។ អរូបឈាន ឈានមានអរូបធម៌ជាអារម្មណ៍, ឈានជា អរូបាវចរ ។

រូបឈានក្តី អរូបឈានក្តី ជាពាក្យសម័យក្រោយ, ពីមុនមកគេហោថា ឈាន និង អារុប្ប ។

## ឈាន ២ យ៉ាងទៀត

**១. អារម្មណូបនិជ្ឈាន** ការសម្លឹងអារម្មណ៍បានដល់សមាបត្តិ ៨ គឺ រូបឈាន ៤ អរូបឈាន ៤ ។

**២. លក្ខណូបនិជ្ឈាន** ការសម្លឹងលក្ខណៈ បានដល់ វិបស្សនា មគ្គ ផល ។

វិបស្សនា ឈ្មោះថា លក្ខណូបនិជ្ឈាន ព្រោះពិនិត្យសង្ខារ ដោយព្រះត្រៃលក្ខណ៍។

មគ្គ ឈ្មោះថា លក្ខណូបនិជ្ឈាន ព្រោះញ៉ាំងកិច្ចនៃវិបស្សនាឱ្យសម្រេច។ ផល ឈ្មោះថា លក្ខណូបនិជ្ឈានព្រោះសម្លឹង ព្រះនិព្វាន ដែលមានលក្ខណៈ ជា សុញ្ញត អនិមិត្ត អប្បណិហិត និង ព្រោះឃើញ លក្ខណៈដែលជាសច្ចភាវៈនៃព្រះនិព្វាន។

## វិមុត្តិ ២ យ៉ាង

**១. ចេតោវិមុត្តិ** ការរួចផុតដោយអំណាចការអប់រំចិត្ត ការរួចផុតនៃចិត្តចាករាគៈ ដោយកម្លាំងនៃសមាធិ។

**២.បញ្ញាវិមុត្តិ** ការរួចផុតដោយអំណាចការចំរើនបញ្ញា ការរួចផុតនៃចិត្តចាកអវិជ្ជា ដោយបញ្ញាដែលឃើញតាមសេចក្តីពិត។

ការរួចផុតចាកកិលេស ដោយការបដិបត្តិ សមថ រហូតដល់បានឈានហើយបដិបត្តិ វិបស្សនា ជាខាងក្រោយរហូតដល់បានសម្រេចអរហត្តផល យ៉ាងនេះ ក៏ហៅថា ចេតោវិមុត្តិ ។

ការរួចផុតចាកកិលេស ដោយការបដិបត្តិ សមថៈ តែមិនទាន់បានសម្រេចឈានទេ ហើយក៏ចាប់ បដិបត្តិ វិបស្សនារហូតបានសម្រេច អរហត្តផល យ៉ាងនេះក៏ហៅថា បញ្ញាវិមុត្តិ ។

## និព្វាន ២ យ៉ាង

**១.សឧបាទិសេសនិព្វាន** និព្វានមាន ឧបាទិ សល់

**២.អនុបាទិសេសនិព្វាន** និព្វានមិនមាន ឧបាទិ សល់។

ឧបាទិ របស់ដែលកិលេសមានឧបាទានជាដើមចូលទៅប្រកាន់មាំ គឺបញ្ចក្ខន្ធ ។ រលត់កិលេស តែបញ្ចក្ខន្ធ នៅសេសសល់ ហៅថា សឧបាទិសេសនិព្វាន ឬ ហៅថា កិលេសនិព្វាន ក៏បាន ។ រលត់កិលេសអស់ហើយ បញ្ចក្ខន្ធ ក៏ រលត់ទៀត យ៉ាងនេះហៅថា អនុបាទិសេសនិព្វាន ឬ ហៅថា ខន្ធនិព្វានក៏បាន ។

## ធម៌ពួក ៣

### សិក្ខា ៣ (ត្រៃសិក្ខា)

**១. សីលសិក្ខា** ការសិក្សា បដិបត្តិឱ្យកើត សីល ដ៏ខ្ពង់ខ្ពស់

**២. ចិត្តសិក្ខា** ការសិក្សា បដិបត្តិឱ្យកើត សមាធិ ដ៏ខ្ពង់ខ្ពស់

**៣. បញ្ញាសិក្ខា** ការសិក្សា បដិបត្តិឱ្យកើត បញ្ញា ដ៏ខ្ពង់ខ្ពស់ ។

សិក្ខា ៣ នេះជួនកាលហៅថា អធិសីលសិក្ខា អធិចិត្តសិក្ខា អធិបញ្ញាសិក្ខា ឬ ហៅឱ្យខ្លីថា សីល សមាធិ បញ្ញា ដូចនេះក៏បាន។

## ត្រៃលក្ខណ៍ លក្ខណៈ ៣

**១. អនិច្ចលក្ខណៈ** លក្ខណៈមិនទៀង ឬ ហៅថា អនិច្ចតា

**២. ទុក្ខលក្ខណៈ** លក្ខណៈជាទុក្ខ ឬ ហៅថា ទុក្ខតា

**៣. អនត្តលក្ខណៈ** លក្ខណៈជាអនត្តា ឬ ហៅថា អនត្តតា។

ព្រះត្រៃលក្ខណ៍នេះ មានឈ្មោះ ហៅម៉្យាងទៀតថា សាមញ្ញលក្ខណៈ លក្ខណៈមានស្មើទូទៅដល់សង្ខារទាំងពួងដូចនេះក៏បាន ។ តាមទម្លាប់គេហៅខ្លីថា អនិច្ចំ ទុក្ខំ អនត្តា ។

## សង្ខតលក្ខណៈ លក្ខណៈនៃសង្ខតធម៌ ៣

**១. ឧប្បាទោ បញ្ញាយតិ** ការកើតឡើងប្រាកដ

**២. វយោ បញ្ញាយតិ** ការសូន្យទៅប្រាកដ

**៣. ឋិតស្ស អញ្ញថត្តំ បញ្ញាយតិ** កាលតាំងនៅ ការប្រែប្រួលប្រាកដ ។

## អសង្ខតលក្ខណៈ លក្ខណៈនៃអសង្ខតធម៌ ៣

**១. ន ឧប្បាទោ បញ្ញាយតិ** ការកើតឡើងមិនប្រាកដ

**២. ន វយោ បញ្ញាយតិ** ការសូន្យទៅមិនប្រាកដ

**៣. ន ឋិតស្ស អញ្ញថត្តំ បញ្ញាយតិ** កាលតាំងនៅការប្រែប្រួលមិនប្រាកដ ។

## និមិត្ត ៣

១. **បរិកម្មនិមិត្ត** គ្រឿងសំគាស់ គឺអារម្មណ៍ ដែលគេយក មកធ្វើជា ទីតម្កល់នៃសតិដើម្បីទប់ចិត្តឱ្យជាសមាធិ ។

២. **ឧគ្គហនិមិត្ត** ភាពចម្លងនៃអារម្មណ៍នោះ ដែលកើតឡើងហាក់ដូចជាជាប់នៅនឹងភ្នែក ។

៣. **បដិភាគនិមិត្ត** ភាពចម្លងនៃអារម្មណ៍នោះដែរ ប៉ុន្តែ មានសភាពបរិសុទ្ធម៉ត់ចត់ជាង ហើយគេអាចពង្រីកឱ្យធំឬពង្រួញ ឱ្យរួមតូចក៏បាន ។

## និមិត្ត ៣

១. **សមាធិនិមិត្ត** សំដៅយកចិត្តដែលផ្តោតខ្លាំងទៅលើអារម្មណ៍របស់សមាធិ ។

២. **បគ្គាហនិមិត្ត** សំដៅយកចិត្តដែលខំប្រឹងព្យាយាមច្រើន ។

៣. **ឧបេក្ខានិមិត្ត** សំដៅយកចិត្តដែលព្រងើយកន្តើយច្រើន ។

## ភាវនា ៣

១.**បរិកម្មភាវនា** សំដៅយកចិត្តក្នុងខណៈចាប់បដិបត្តិសមាធិដំបូងៗ មិនទាន់ស្ងប់ ឬ ស្ងប់តិចៗ ។

២. **ឧបចារភាវនា** សំដៅយកចិត្តក្នុងខណៈដែលកើតបដិភាគ

និមិត្តស្ងប់ចាកនីវរណធម៌ ។ ភាវនាទាំងពីរនេះបដិបត្តិមក ត្រឹមនេះចាត់ជា កាមាវចរសមាធិ ។

៣. **អប្បនាភាវនា** សំដៅយកចិត្តដែលឆ្លងចាកគោត្រភូខណៈ ក្នុងឈានជវនៈ បានសម្រេច រូបជ្ឈាន អរូបជ្ឈាន។ភាវនា នេះ ចាត់ជារូបាវចរសមាធិ អរូបាវចរសមាធិ ។

## ភាវនា ៣

១. **កាយភាវនា** ការអប់រំកាយ

២. **ចិត្តភាវនា** ការអប់រំចិត្ត

៣. **បញ្ញាភាវនា** ការអប់រំបញ្ញា ។

## សមាធិ ៣

១.**ខណិកសមាធិ** ចិត្តស្ងប់ជា ខណៈៗ គឺស្ងប់តិចៗ

២.**ឧបចារសមាធិ** ចិត្តស្ងប់យូរក្រែលក្បែរៗអប្បនាសមាធិ។

៣.**អប្បនាសមាធិ** ចិត្តស្ងប់នីវរណធម៌ ឬបានរូបជ្ឈាន អរូប ជ្ឈាន។

## សមាធិ ៣

១.**សវិតក្កវិចារសមាធិ** សមាធិមានវិតក្ក មានវិចារៈ

២. **អវិតក្កវិចារមត្តសមាធិ** សមាធិមិនមានវិតក្ក មានត្រឹម

តែវិចារៈ

៣. **អវិតក្កវិចារសមាធិ** សមាធិមិនមានវិតក្ក មិនមានវិចារៈ។

## សមាធិ ៣

១. **សុញ្ញតសមាធិ** សមាធិមាន អនត្តា ជាអារម្មណ៍

២. **អនិមិត្តសមាធិ** សមាធិមាន អនិច្ចំ ជាអារម្មណ៍

៣. **អប្បណិហិតសមាធិ** សមាធិមាន ទុក្ខំ ជាអារម្មណ៍ ។

## វិមោក្ខ ៣

១. **សុញ្ញតវិមោក្ខ** ការរួចផុតព្រោះឃើញ អនត្តា

២. **អនិមិត្តវិមោក្ខ** ការរួចផុតព្រោះឃើញ អនិច្ចំ

៣. **អប្បណិហិតវិមោក្ខ** ការរួចផុតព្រោះឃើញ ទុក្ខំ។

## បញ្ញា ៣

១.**សុតាមយបញ្ញា** បញ្ញាកើតមកអំពីការស្តាប់

២. **ចិន្តាមយបញ្ញា** បញ្ញាកើតមកអំពីការគិត

៣. **ភាវនាមយបញ្ញា** បញ្ញាកើតមកអំពីការហ្វឹកហាត់ បដិបត្តិ។

## ញាណ ៣

**១. សច្ចញាណ** ញាណដឹងសច្ចទាំង ៤ គឺដឹងថា នេះទុក្ខ នេះហេតុឱ្យទុក្ខកើត នេះការរលត់ទុក្ខ នេះផ្លូវដើរទៅរកការរលត់ទុក្ខ។

**២. កិច្ចញាណ** ញាណដឹងកិច្ចដែលត្រូវធ្វើក្នុងសច្ចៈទាំង ៤ ទុក្ខ មានកិច្ចដែលគេគប្បីកំណត់ដឹង, សមុទយៈមានកិច្ចដែលគេត្រូវលះបង់, និរោធ មានកិច្ចដែលគេត្រូវធ្វើឱ្យជាក់ច្បាស់, មគ្គ មានកិច្ចដែលគេត្រូវចម្រើន គឺបដិបត្តិតាម។

**៣. កតញាណ** ញាណដឹងថា បានធ្វើស្រេចហើយក្នុង សច្ចៈទាំង ៤ គឺទុក្ខ គេបានកំណត់ដឹងហើយ, សមុទយៈ គេបានលះបង់ហើយ, និរោធៈ គេបានធ្វើឱ្យជាក់ច្បាស់ហើយ, មគ្គ គេបានចម្រើនហើយ។

ញាណ ៣ នេះក្នុងអរិយសច្ច ហៅថាញាណទស្សនៈ វិលជុំទាំង ៣ ហៅថា បរិវដ្តៈ គ្រប់សច្ចៈទាំង ៤ ត្រូវជា ១២ ហៅថាអាការៈ។

## វិជ្ជា ៣

**១. បុព្វេនិវាសានុស្សតិញ្ញាណ** ញាណដែលដឹងច្បាស់រឭកជាតិបាន។

២. **ចុតូបបាតញ្ញាណ** ញាណដឹងច្បាស់ការច្យុតិ និង ការកើត
របស់សត្វទាំងឡាយ ។

៣. **អាសវក្ខយញ្ញាណ** ញាណដឹងច្បាស់ក្នុងធម៌ជាទីអស់ទៅ
នៃអាសវៈ ។ វិជ្ជា ៣ នេះ តាមទម្លាប់ គេប្រើពាក្យថា
ញាណ ជំនួស ។

## **ភព ៣**

១. **កាមភព** ភពរបស់អ្នកសេពកាមគុណ (កាមាវចរ )

២. **រូបភព** ភពរបស់អ្នកចូលដល់រូបជ្ឈាន ( រូបាវចរ )

៣. **អរូបភព** ភពរបស់អ្នកចូលដល់អរូបជ្ឈាន ( អរូបាវចរ )។

## **តណ្ហា ៣**

១. **កាមតណ្ហា** ចំណង់ក្នុងកាមគុណ

២. **ភវតណ្ហា** ចំណង់ក្នុងភព ( ប្រកបដោយ ភវទិដ្ឋិ និង
សស្សតទិដ្ឋិ )

៣. **វិភវតណ្ហា** ចំណង់ក្នុងវិភព ( ប្រកបដោយ វិភវទិដ្ឋិ និង
ឧច្ឆេទទិដ្ឋិ )។



## **វដ្ដៈ ៣**

១. **កិលេសវដ្ដៈ** គ្រឿងវិល គឺកិលេស បានដល់ អវិជ្ជា តណ្ហា ឧបាទាន

២. **កម្មវដ្ដៈ** គ្រឿងវិល គឺកម្ម បានដល់ សង្ខារ និង កម្មភព

៣. **វិបាកវដ្ដៈ** គ្រឿងវិល គឺវិបាក បានដល់ វិញ្ញាណ នាម រូប សឡាយតនៈ ផស្សៈ វេទនា ឧបបត្តិភព ជាតិ ជរា មរណៈ ជាដើម ។

## **បបញ្ចធម៌ ៣**

១. **តណ្ហា** ចំណង់មិនចេះចប់ គឺមិនឆ្អែត

២.**ទិដ្ឋិ** ជឿតែគំនិតខ្លួន

៣. **មានះ** ប្រកាន់ថា គ្មាននរណាស្មើជាដើម។

ធម៌ ៣ នេះនាំឱ្យយឺតយូរ ទើបលោកហៅថា បបញ្ចធម៌។

## **អបណ្ណកបដិបទា ៣**

១. **ឥន្ទ្រិយសំវរៈ** សង្រួមឥន្ទ្រិយ៍ ទាំង ៦ មានភ្នែកជាដើម។

២. **ភោជនេ មត្តញ្ញុតា** ស្គាល់ប្រមាណក្នុងភោជន

៣. **ជាគរិយានុយោគ** ប្រព្រឹត្តរឿយ ៗ ជាអ្នកភ្ញាក់រឭក ខំប្រឹងប្រែង ។ អបណ្ណកបដិបទា បដិបត្តិមិនខុស នរណាក៏បដិបត្តិបាន ។

## សង្ខារ ៣

១. **កាយសង្ខារ** សភាវៈតាក់តែងកាយ បានដល់អស្សាស បស្សាសៈ ខ្យល់ដកដង្ហើមចូល ដកដង្ហើមចេញ(អានាបានៈ)។

២. **វចីសង្ខារ** សភាវៈតាក់តែងវាចាបានដល់ វិតក្ក វិចារៈ។

៣. **ចិត្តសង្ខារ** សភាវៈតាក់តែងចិត្តបានដល់ សញ្ញា វេទនា។

សង្ខារ ៣ នេះគេច្រើននិយាយក្នុងរឿងសញ្ញាវេទយិតនិរោធ។

## សង្ខារ ៣

១. **កាយសង្ខារ** សភាវៈតាក់តែងការធ្វើផ្លូវកាយ បានដល់កាយសញ្ចេតនា។

២. **វចីសង្ខារ** សភាវៈតាក់តែងការធ្វើផ្លូវវាចា បានដល់វចីសញ្ចេតនា។

៣. **ចិត្តសង្ខារ ឬ មនោសង្ខារ** សភាវៈតាត់តែងការធ្វើផ្លូវចិត្ត បានដល់ មនោសញ្ចេតនា។

សង្ខារ ៣ នេះមានសេចក្តី ទំនាក់ទំនងនឹងពាក្យថាសង្ខារក្នុងបដិច្ចសមុប្បាទ។

## អភិសង្ខារ ៣

១. **បុញ្ញាភិសង្ខារ** សភាវៈតាក់តែងកម្មល្អ បានដល់កុសល

ចេតនា ជាកាមាវចរ និង រូបាវចរ ។

២. **អបុញ្ញាភិសង្ខារ** សភាវៈ តាក់តែងកម្មអាក្រក់ បានដល់ អកុសលចេតនាទាំងឡាយ។

៣. **អនេញ្ជាភិសង្ខារ** សភាវៈតាក់តែងកម្មមិនញាប់ញ័រ បាន ដល់កុសលចេតនា ជាអរូបាវចរ ។

អភិសង្ខារ ៣ នេះ ជាអត្ថន័យ របស់ពាក្យ សង្ខារក្នុង បដិច្ចសមុប្បាទ ។

## វិវេក ៣

១. **កាយវិវេក** សេចក្ដីស្ងប់កាយ គឺ នៅក្នុងទីស្ងាត់ម្នាក់ឯង

២. **ចិត្តវិវេក** សេចក្ដីស្ងប់ចិត្ត គឺ ចិត្តស្ងប់ចាក នីវរណធម៌ សំយោជនៈ និងអនុស័យជាដើម បានដល់ចិត្តរបស់បុគ្គល ដែលបានសម្រេចឈាន អរិយមគ្គ អរិយផល ។

៣. **ឧបធិវិវេក** សេចក្ដីស្ងប់ចាក ឧបធិ គឺធម៌ជាទីស្ងប់រម្ងាប់ នូវសង្ខារទាំងពួង ប្រាសចាកកិលេសក្តី ខន្ធក្តី អភិសង្ខារក្តី សំដៅយក ព្រះនិព្វាន។

## វេទនា ៣

១. **សុខវេទនា** ការទទួលដឹង (សោយ) សេចក្ដីសុខ

**២. ទុក្ខវេទនា** ការទទួលដឹង (សោយ) សេចក្តីទុក្ខ

**៣. អទុក្ខមសុខវេទនា** ការទទួលដឹង (សោយ) សេចក្តីមិនទុក្ខ មិនសុខ។

## អាសវៈ ៣

**១. កាមាសវៈ** អាសវៈគឺកាម សភាវៈ ដែលហូរជ្រាបចូលទៅ ឬត្រាំនៅក្នុងចិត្ត។

**២. ភវាសវៈ** អាសវៈគឺ ភព សភាវៈដែលហូរជ្រាបចូលទៅ ឬត្រាំនៅក្នុងចិត្ត។

**៣. អវិជ្ជាសវៈ** អាសវៈ គឺ អវិជ្ជា សភាវៈ ដែលហូរជ្រាបចូលទៅ ឬ ត្រាំនៅក្នុងចិត្ត។

## និព្វាន ៣

**១. កិលេសនិព្វាន** រលត់កិលេស

**២. ខន្ធនិព្វាន** រលត់ខន្ធ

**៣. ធាតុនិព្វាន** រលត់ព្រះធាតុ។

## កិញ្ចនៈ ៣

**១. រាគកិញ្ចនៈ** គ្រឿងកង្វល់ គឺរាគៈ

**២. ទោសកិញ្ចនៈ** គ្រឿងកង្វល់ គឺទោសៈ

**៣. មោហកិញ្ចនៈ** គ្រឿងកង្វល់ គឺ មោហៈ។

## ធាតុ ៣

**១. រូបធាតុ** ធាតុ គឺ អ្វីដែលចាត់ជា រូប

**២. អរូបធាតុ** ធាតុ គឺ អ្វីដែលមិនចាត់ជារូប គឺ នាម

**៣. និរោធធាតុ** ធាតុ គឺ ការរលត់ មិនមែនជារូប មិនមែនជានាម គឺ ព្រះនិព្វាន ។

## ធម៌ពួក ៤

## ធាតុ ៤

**១. បឋវីធាតុ** ធាតុដី

**២. អាបោធាតុ** ធាតុទឹក

**៣. តេជោធាតុ** ធាតុភ្លើង

**៤. វាយោធាតុ** ធាតុខ្យល់

ធាតុ ៤ នេះជួនកាល គេហៅថា មហាភូតរូប រូបធំៗ ជាទីប្រជុំ ជាមេនៃវត្ថុធាតុទាំងឡាយ នេះជាធាតុ ៤ ខាងក្រៅ។ចំណែករូបកាយយើង ក៏ធាតុ ៤ ដែរ ប៉ុន្តែជាធាតុខាងក្នុង។

# សតិប្បដ្ឋាន ៤

ធម៌ជាទីតាំងនៃសតិ ដើម្បីទប់ចិត្តឱ្យនៅនឹងមួយកន្លែងហើយ ពិចារណាឱ្យឃើញនូវធម៌នោះតាមសេចក្ដីពិត កំចាត់បង់នូវអភិជ្ឈា និង ទោមនស្ស មិនមានតណ្ហា ឧបាទាន ក្នុងអ្វីទាំងអស់។ ធម៌នោះ ហៅថា សតិប្បដ្ឋាន មាន ៤ គឺ

**១. កាយ** ឬ ហៅថាកាយានុបស្សនាសតិប្បដ្ឋាន

**២. វេទនា** ឬ ហៅថា វេទនានុបស្សនាសតិប្បដ្ឋាន

**៣. ចិត្ត** ឬ ហៅថា ចិត្តានុបស្សនាសតិប្បដ្ឋាន

**៤. ធម៌** ឬ ហៅថា ធម្មានុបស្សនាសតិប្បដ្ឋាន ។

ពាក្យថា កាយ ចែកចេញជា ៦ គឺ ១. អានាបានៈ ខ្យល់ដង្ហើមចេញ ចូល, ២. ឥរិយាបថៈ ឥរិយាបថ ៤ ដើរ ឈរ អង្គុយ ដេក, ៣. សម្បជញ្ញៈ មានសតិសម្បជញ្ញៈ ដឹងទាន់គ្រប់សកម្មភាពឈានទៅមុខ ថយក្រោយ ងាកស្ដាំ ងាកឆ្វេង ជាដើម, ៤. បដិកូល ពិចារណារូបកាយ សក់ រោម ក្រចក ធ្មេញ ស្បែក ជាដើមឱ្យឃើញជាបដិកូល គួរខ្ពើម, ៥. ធាតុ ពិចារណារូបកាយឱ្យឃើញជាធាតុ ៤, ៦. នវសីវថិកា ពិចារណាសាកសព ៩ បែប ។

វេទនា ចែកចេញជា ៣ គឺ សុខវេទនា ទុក្ខវេទនា អទុក្ខមសុខវេទនា ប្រកបដោយអាមិសក្ដី មិនប្រកបដោយអាមិសក្ដី ។

ចិត្ត ចែកចេញជា ១៦ គឺ ចិត្តមានរាគៈ (សរាគៈ), ចិត្តមិនមានរាគៈ(វីតរាគៈ),ចិត្តមានទោសៈ,ចិត្តមិនមានទោសៈ,ចិត្តមានមោហៈ ចិត្តមិនមានមោហៈ, ចិត្តរួញរា (សង្ខិត្ត), ចិត្តរាយមាយ(វិក្ខិត្ត), ចិត្តដល់នូវភាពជាធំ(មហគ្គតៈ), ចិត្តមិនដល់នូវភាពជាធំ (អមហគ្គត), ចិត្តនៅមានចិត្តដទៃប្រសើរជាង(សឧត្តរ), ចិត្តមិនមានចិត្តដទៃប្រសើរជាង(អនុត្តរ), ចិត្តតាំងនៅមាំ(សមាហិត), ចិត្តមិនតាំងនៅមាំ(អសមាហិត), ចិត្តរួចផុត (វិមុត្ត), ចិត្តមិនទាន់រួចផុត(អវិមុត្ត)។

ធម៌. ចែកចេញជា ៥ គឺ នីវរណៈ ៥ , ខន្ធ ៥, អាយតនៈ ១២, ពោជ្ឈង្គ ៧ , សច្ចៈ ៤ ។

## សម្មប្បធាន ៤

១. **សំវរបធាន** ព្យាយាមបិទទប់បាបអកុសល ដែលមិនទាន់កើត មិនឱ្យកើតឡើងបាន ។

២. **បហានបធាន** ព្យាយាមលះបាបអកុសលដែលកើតឡើងហើយ។

៣. **ភាវនាបធាន** ព្យាយាមចំរើនបុណ្យកុសល ដែលមិនទាន់កើត ឱ្យកើតឡើង ។

៤. **អនុរក្ខនាបធាន** ព្យាយាមថែរក្សាបុណ្យកុសល ដែលកើតឡើងហើយ ឱ្យតាំងនៅមាំ និងធ្វើឱ្យរឹតតែរីកចម្រើនឡើងជា

ភិយ្យោភាពទៀត ។

បធាន សម្មប្បធាន និង សម្មាវាយាម ប្រើជំនួសគ្នាបាន។

## ឥទ្ធិបាទ ៤

១. **ឆន្ទៈ** សេចក្តីពេញចិត្ត បំណង

២. **វីរិយៈ** សេចក្តីព្យាយាម

៣. **ចិត្ត** ការយកចិត្តទុកដាក់ គំនិត

៤. **វិមំសា** ការត្រិះរិះពិចារណា។

ឥទ្ធិបាទទាំង ៤ នេះ ជាធម៌នាំឱ្យសម្រេចកិច្ចការផ្សេងៗ បើកិច្ចការនោះមិនហួសវិស័យទេ ។ ចំពោះអ្នកបដិបត្តិធម៌ ព្រះពុទ្ធប្រៀនប្រដៅឱ្យចម្រើនឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិ និង បធានសង្ខារ ប្រកបដោយវីរិយសមាធិ និង បធានសង្ខារប្រកបដោយចិត្តសមាធិ... ប្រកបដោយវិមំសាសមាធិ និង បធានសង្ខារ។

## ឱឃៈ ៤

១. **កាមោឃៈ** អន្លង់ គឺ កាម

២. **ភវោឃៈ** អន្លង់ គឺ ភព

៣. **ទិដ្ឋោឃៈ** អន្លង់ គឺ ទិដ្ឋិ

៤. **អវិជ្ជោឃៈ** អន្លង់ គឺ អវិជ្ជា ។

## **អាសវៈ ៤**

១. **កាមាសវៈ** អាសវៈ គឺ កាម

២. **ភវាសវៈ** អាសវៈ គឺ ភព

៣. **ទិដ្ឋាសវៈ** អាសវៈ គឺ ទិដ្ឋិ

៤. **អវិជ្ជាសវៈ** អាសវៈ គឺ អវិជ្ជា

បើសង្គ្រោះត្រឹម ៣ ទិដ្ឋាសវៈ ចូលជាមួយ ភវាសវៈ ។

## **ឧបាទាន ៤**

១. **កាមុបាទាន** ប្រកាន់មាំក្នុងកាម

២. **ទិដ្ឋុបាទាន** ប្រកាន់មាំក្នុងទិដ្ឋិ

៣. **សីលព្វតុបាទាន** ប្រកាន់មាំក្នុងសីល និង វត្ត ព្រមទាំងប្រពៃណីផ្សេងៗ និង វត្ថុសក្តិសិទ្ធិខ្លាំងពូកែ ។

៤. **អត្តវាទុបាទាន** ប្រកាន់មាំក្នុងវាទៈថា មានខ្លួន។

## **ព្រហ្មវិហារ ៤**

១. **មេត្តា** សេចក្តីស្រឡាញ់រាប់អាន

២. **ករុណា** សេចក្តីអាណិតអាសូរ

៣. **មុទិតា** សេចក្តីរីករាយជាមួយនឹងសេចក្តីល្អរបស់អ្នកដទៃ

៤. **ឧបេក្ខា** ការតាំងចិត្តជាកណ្តាល ។

បើផ្សាយទៅដោយមិនមានព្រំដែនហៅថា អប្បមញ្ញា។

## បរមត្ថធម៌ ៤

**១. ចិត្ត** សភាវៈដឹងអារម្មណ៍
**២. ចេតសិក** សភាវៈប្រកបជាមួយចិត្ត
**៣. រូប** សភាវៈជារូបមិនដឹងអារម្មណ៍
**៤. និព្វាន** សភាវៈដែលអស់កិលេស និង ទុក្ខ ។

## អវិជ្ជា ៤

**១. ទុក្ខេ អញ្ញាណំ** មិនដឹងច្បាស់ទុក្ខ
**២. ទុក្ខសមុទយេ អញ្ញាណំ** មិនដឹងច្បាស់ហេតុឱ្យទុក្ខកើត
**៣. ទុក្ខនិរោធេ អញ្ញាណំ** មិនដឹងច្បាស់ការរលត់ទុក្ខ
**៤. ទុក្ខនិរោធគាមិនិយា បដិបទាយ អញ្ញាណំ** មិនដឹងច្បាស់បដិបទាឱ្យដល់នូវការរលត់ទុក្ខ។

## ភាវនា ៤

**១. កាយភាវនា** ចម្រើនកាយ
**២. សីលភាវនា** ចម្រើនសីល
**៣. ចិត្តភាវនា** ចម្រើនចិត្ត

**៤. បញ្ញាភាវនា** ចម្រើនបញ្ញា ។

## បដិបទា ៤

**១. ទុក្ខាបដិបទា ទន្ធាភិញ្ញា** បដិបត្តិពិបាក ត្រាស់ដឹងយឺតយូរ
**២. ទុក្ខាបដិបទា ខិប្បាភិញ្ញា** បដិបត្តិពិបាក ត្រាស់ដឹងឆាប់
**៣.សុខាបដិបទា ទន្ធាភិញ្ញា** បដិបត្តិស្រួល ត្រាស់ដឹងយឺតយូរ
**៤.សុខាបដិបទា ខិប្បាភិញ្ញា** បដិបត្តិស្រួល ត្រាស់ដឹងឆាប់។

## បដិបទា ៤

**១. អក្ខមា បដិបទា** បដិបត្តិមិនអត់ធន់
**២. ខមា បដិបទា** បដិបត្តិអត់ធន់
**៣. ទមា បដិបទា** បដិបត្តិទូន្មាន
**៤. សមា បដិបទា** បដិបត្តិស្ងប់រម្ងាប់។

## សង្ខារ ៤

**១. សង្ខតសង្ខារ** សង្ខារកើតចាកបច្ច័យតាក់តែង
**២. អភិសង្ខតសង្ខារ** សង្ខារកើតពីកម្មតាក់តែង
**៣. អភិសង្ខរណកសង្ខារ** សង្ខារគឺកម្មដែលជាតួតាក់តែង
**៤. បយោគាភិសង្ខារ** សង្ខារគឺការប្រកបសេចក្តីព្យាយាម។

## សម្បជញ្ញៈ ៤

១. **សាត្ថកសម្បជញ្ញៈ** ដឹងច្បាស់ថាមានប្រយោជន៍
២. **សប្បាយសម្បជញ្ញៈ** ដឹងច្បាស់ថាសប្បាយគឺគួរសមដល់ខ្លួន
៣. **គោចរសម្បជញ្ញៈ** ដឹងច្បាស់ថាជាគោចរគឺការងាររបស់ខ្លួន
៤. **អសម្មោហសម្បជញ្ញៈ** ដឹងច្បាស់ថាមិនវង្វេង ។

## ចតុប្បារិសុទ្ធិសីល ៤

១. **បាដិមោក្ខសំវរសីល** សីលគឺការសង្រួមក្នុងបាដិមោក្ខ
២. **ឥន្ទ្រីយសំវរសីល** សីលគឺការសង្រួមឥន្ទ្រីយ៍
៣. **អាជីវបារិសុទ្ធិសីល** សីលគឺការបរិសុទ្ធិនៃអាជីវៈ
៤. **បច្ចយសន្និស្សិតសីល** សីលអាស្រ័យការប្រើប្រាស់បច្ច័យដោយបាន ពិចារណា។

## រូបជ្ឈាន ៤

១. **បឋមជ្ឈាន** មានអង្គ ៥ គឺ វិតក្ក វិចារ បីតិ សុខ ឯកគ្គតា
២. **ទុតិយជ្ឈាន** មានអង្គ ៣ គឺ បីតិ សុខ ឯកគ្គតា
៣. **តតិយជ្ឈាន** មានអង្គ ២ គឺ សុខ ឯកគ្គតា
៤. **ចតុត្ថជ្ឈាន** មានអង្គ ២ គឺ ឧបេក្ខា ឯកគ្គតា។

ឈាន ៤ នេះ គម្ពីរអភិធម្មចែកជា ៥ ដោយចែក បឋមឈានជាពីរ ព្រោះអ្នកបញ្ញាខ្សោយ លះអង្គឈានបានម្តងតែមួយប៉ុណ្ណោះ។ ឈាន ៤ ឈ្មោះថា ចតុក្កន័យ ឈាន ៥ ឈ្មោះថា បញ្ចក្កន័យ។

## អរូបជ្ឈាន ៤

១. **អាកាសានញ្ចាយតន** កំណត់អាកាសជាអារម្មណ៍
២. **វិញ្ញាណញ្ចាយតន** កំណត់វិញ្ញាណជាអារម្មណ៍
៣. **អាកិញ្ចញ្ញាយតន** កំណត់ភាវៈមិនមានអ្វីជាអារម្មណ៍
៤. **នេវសញ្ញានាសញ្ញាយតន** មានសញ្ញាជាអារម្មណ៍ ក៏មិនមែន មិនមានសញ្ញាជាអារម្មណ៍ក៏មិនមែន ។

## សមាធិ ៤

១. **ហានភាគិយសមាធិ** សមាធិមានចំណែកសាបសូន្យ
២. **ឋិតិភាគិយសមាធិ** សមាធិមានចំណែកតាំងនៅ
៣. **វិសេសភាគិយសមាធិ** សមាធិមានចំណែកវិសេស
៤. **និព្វេធភាគិយសមាធិ** សមាធិមានចំណែកចាក់ធ្លុះ ។

## អរិយសច្ច ៤

១. **ទុក្ខសច្ច** ជាតិ ជរា មរណៈ ....

**២. សមុទយសច្ច** តណ្ហា ៣

**៣. និរោធសច្ច** លះតណ្ហា៣ និព្វាន

**៤. មគ្គសច្ច** មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ។

## មគ្គ ៤

**១. សោតាបត្តិមគ្គ**

**២.សកទាគាមិមគ្គ**

**៣. អនាគាមិមគ្គ**

**៤. អរហត្តមគ្គ**

មគ្គក្នុងទីនេះ សំដៅយកបញ្ញាដែលកើតពីការឃើញមគ្គអាចកំចាត់សំយោជនកិលេស ជាសមុច្ឆេទប្បហានបាន ។

## ផល ៤

**១. សោតាបត្តិផល**

**២. សកទាគាមិផល**

**៣. អនាគាមិផល**

**៤. អរហត្តផល**

ផលក្នុងទីនេះ ជាធម្មារម្មណ៍ដែលព្រះអរិយបុគ្គល គប្បីសោយ ជាផលកើតឯងក្នុងកាលដែលលះកិលេសអស់ ដោយអំណាចមគ្គនោះ ។

## ផលនៃសមាធិភាវនា ៤

**១. ទិដ្ឋធម្មសុខវិហារ** ដើម្បីសេចក្ដីសុខក្នុងបច្ចុប្បន្ន

**២. ញាណទស្សន** ដើម្បីបានញាណទស្សនៈ

**៣. សតិសម្បជញ្ញ** ដើម្បីបានសតិសម្បជញ្ញៈ

**៤. អាសវក្ខយ** ដើម្បីអស់អាសវៈ។

## ពួកធម៌ ៥

## ខន្ធ ៥

**១. រូប** រូបធាតុ ឬ ធាតុមិនដឹង ធាតុវិនាសដោយក្ដៅ...

**២. វេទនា** សភាវៈមិនមានរូប តែដឹង សុខ ទុក្ខ

**៣. សញ្ញា** សភាវៈមិនមានរូប តែដឹងកត់ចំណាំ

**៤. សង្ខារ** សភាវៈមិនមានរូប តែដឹងគិតគូរ

**៥. វិញ្ញាណ** សភាវៈមិនមានរូប តែដឹង ឃើញ ឮជាដើម។

ខន្ធ ៥ នេះ បង្រួញឱ្យខ្លីមានតែ ២ គឺ រូប នាម ។ រូប គឺ រូប។ វេទនា សញ្ញា សង្ខារ វិញ្ញាណ ជានាម គឺមានតែឈ្មោះ និង ការដឹងអារម្មណ៍តែប៉ុណ្ណោះ ។ មនុស្សយើង គឺ ខន្ធ ៥ នេះឯង។ ក្នុងត្រៃលោក មានតែរូបនាមប៉ុណ្ណោះ ។

## ឧបាទានក្ខន្ធ ៥

**១. រូបូបាទានក្ខន្ធ** សេចក្ដីប្រកាន់មាំក្នុងរូប
**២. វេទនូបាទានក្ខន្ធ** សេចក្ដីប្រកាន់មាំក្នុងវេទនា
**៣. សញ្ញូបាទានក្ខន្ធ** សេចក្ដីប្រកាន់មាំក្នុងសញ្ញា
**៤. សង្ខារូបាទានក្ខន្ធ** សេចក្ដីប្រកាន់មាំក្នុងសង្ខារ
**៥. វិញ្ញាណូបាទានក្ខន្ធ** សេចក្ដីប្រកាន់មាំក្នុងវិញ្ញាណ។

## កាមគុណ ៥

**១. រូប** ជាទីស្រឡាញ់ ជាទីគាប់ចិត្ត
**២. សម្លេង** ជាទីស្រឡាញ់ ជាទីគាប់ចិត្ត
**៣. ក្លិន** ជាទីស្រឡាញ់ ជាទីគាប់ចិត្ត
**៤. រស** ជាទីស្រឡាញ់ ជាទីគាប់ចិត្ត
**៥. ផោដ្ឋព្វៈ** ជាទីស្រឡាញ់ ជាទីគាប់ចិត្ត។

## នីវរណៈ ៥

ធម៌ជាគ្រឿងរារាំងមិនឱ្យចម្រើន មិនឱ្យស្ងប់ មិនឱ្យកើតបញ្ញា ហៅថា នីវរណៈ មាន ៥ គឺៈ

**១. កាមច្ឆន្ទ** សេចក្ដីពេញចិត្តក្នុងកាម
**២. ព្យាបាទ** គំនុំ ឬ សេចក្ដីប្រទូសរ៉ាយ

**៣. ថីនមិទ្ធ** សេចក្ដីធុញទ្រាន់ ងោកងុយ

**៤. ឧទ្ធច្ចកុក្កុច្ច** សេចក្ដីអណ្ដែតអណ្ដូង ( រាយមាយ ) រសាប់រសល់

**៥.វិចិកិច្ឆា** សេចក្ដីសង្ស័យ។

## ឧបមានីវរណៈ ៥

**១. កាមច្ឆន្ទ** ប្រៀបដូច ទឹកមានពណ៌ផ្សេង ៗ

**២. ព្យាបាទ** ប្រៀបដូច ទឹកពុះ

**៣. ថីនមិទ្ធ** ប្រៀបដូច ទឹកមានចកសារ៉ាយ

**៤. ឧទ្ធច្ចកុក្កុច្ច** ប្រៀបដូច ទឹករលក

**៥.វិចិកិច្ឆា** ប្រៀបដូច ទឹកល្អក់ ។

## ឧបមានីវរណៈ ៥

**១. កាមច្ឆន្ទ** ប្រៀបដូចជំពាក់បំណុលគេ

**២. ព្យាបាទ** ប្រៀបដូចកើតរោគ

**៣. ថីនមិទ្ធ** ប្រៀបដូចជាប់គុក

**៤. ឧទ្ធច្ចកុក្កុច្ច** ប្រៀបដូចធ្វើទាសៈ

**៥.វិចិកិច្ឆា** ប្រៀបដូចដើរផ្លូវឆ្ងាយ

## អាហាររបស់នីវរណៈ ៥

**១. សុភនិមិត្ត** ការកំណត់ថា ល្អ ថាស្អាត ជាអាហារ របស់កាមច្ឆន្ទ

**២. បដិឃៈ** ការទើសចិត្ត ជាអាហាររបស់ ព្យាបាទ

**៣. អរតិ** សេចក្តីមិនត្រេកអរ តន្ទិ សេចក្តីខ្ជិល ភត្តសម្មទ ការពុលបាយ ជាអាហាររបស់ ថីនមិទ្ធ

**៤. ចេតសោ អវូបសម** ការមិនចូលទៅស្ងប់រម្ងាប់ចិត្ត ជា អាហាររបស់ ឧទ្ធច្ចកុក្កុច្ច

**៥. អយោនិសោមនសិការ** ការមិនធ្វើទុកក្នុងចិត្តដោយ ឧបាយនៃប្រាជ្ញា ជាអាហាររបស់ វិចិកិច្ឆា។

## ធម៌កំចាត់នីវរណៈ ៥

**១. អសុភនិមិត្ត** ការកំណត់ថា មិនល្អ មិនស្អាត កំចាត់ កាមច្ឆន្ទៈ

**២. មេត្តា** សេចក្តីស្រឡាញ់រាបអាន កំចាត់ ព្យាបាទ

**៣. អារម្ភធាតុ** ធាតុផ្តួចផ្តើម និក្កមធាតុ ធាតុព្យាយាម បរក្កធាតុ ធាតុប្រឹងប្រែង កំចាត់ ថីនមិទ្ធៈ

**៤. ចេតសោវូបសម** ការចូលទៅស្ងប់រម្ងាប់ចិត្ត កំចាត់ ឧទ្ធច្ចកុក្កុច្ច

**៥. យោនិសោមនសិការ** ការធ្វើទុកក្នុងចិត្តដោយ ឧបាយនៃប្រាជ្ញា កំចាត់ វិចិកិច្ឆា ។

## អង្គឈានកំចាត់នីវរណៈ ៥

**១. វិតក្ក** កំចាត់ ថីនមិទ្ធៈ

**២. វិចារៈ** កំចាត់ វិចិកិច្ឆា

**៣. បីតិ** កំចាត់ ព្យាបាទ

**៤. សុខៈ** កំចាត់ ឧទ្ធច្ចកុក្កុច្ច

**៥. ឯកគ្គតា (សមាធិ)** កំចាត់ កាមច្ឆន្ទ។

## ឱរម្ភាគិយសំយោជនៈ ៥

**១. សក្កាយទិដ្ឋិ** សេចក្តីយល់ឃើញថាជាកាយរបស់ខ្លួន

**២. វិចិកិច្ឆា** សេចក្តីសង្ស័យ

**៣. សីលព្វត្តបរាមាស** ការប្រកាន់មាំក្នុងសីល និង វត្តព្រមទាំងពិធីផ្សេងៗ ជាដើម

**៤. កាមច្ឆន្ទ** សេចក្តីពេញចិត្តក្នុងកាម

**៥. ព្យាបាទ** គំនុំ សេចក្តីប្រទូសរ៉ាយ ។

## **ឧទ្ធម្ភាគិយសំយោជនៈ ៥**

**១. រូបរាគ** សេចក្តីត្រេកអរក្នុងរូប

**២. អរូបរាគ** សេចក្តីត្រេកអរក្នុងអរូប

**៣. មានៈ** សេចក្តីប្រកាន់

**៤. ឧទ្ធច្ចៈ** សេចក្តីរាយមាយ

**៥. អវិជ្ជា** សេចក្តីមិនដឹង

**គួរកត់ចំណាំ** គេអាចប្រើ កាមរាគ ជំនួស កាមច្ឆន្ទ បដិឃ ជំនួស ព្យាបាទ។ និងមានរៀបរាប់ខុសពីនេះខ្លះទៀតក៏មាន។

## **បីតិ ៥**

**១. ខុទ្ទកាបីតិ** សេចក្តីឆ្អែតចិត្តតិចៗធ្វើឱ្យព្រឺរោម ឬឱ្យចេញទឹកភ្នែក

**២. ខណិកាបីតិ** សេចក្តីឆ្អែតចិត្តជាខណៈៗព្រឺរោមខ្លាកៗដូចផ្លេកបន្ទោរ

**៣. ឱក្កន្តិកាបីតិ** សេចក្តីឆ្អែតចិត្តប៉ះម្តងៗ ដូចរលកផ្ទប់ច្រាំង។

**៤. ឧពេង្គាបីតិ** សេចក្តីឆ្អែតចិត្តធ្វើ ឱ្យហាក់ដូចជាអណ្តែតខ្លួន ឬ អាចបញ្ចេញអាកប្បកិរិយា ឬ បញ្ចេញវាចាដោយឥតមានចេតនា។

**៥. ផរណាបីតិ** សេចក្តីឆ្អែតចិត្តធ្វើឱ្យស្រួលជ្រួតជ្រាបសព្វ

សព៌ាង្គកាយ ។

## **ឥន្ទ្រីយ ៥**

១. **សទ្ធិន្ទ្រីយ** សទ្ធា ជាធំក្នុងជំនឿ
២. **វីរិយិន្ទ្រីយ** វីរិយ ជាធំក្នុងសេចក្តីព្យាយាម
៣. **សតិន្ទ្រីយ** សតិ ជាធំក្នុងការនឹករឭក
៤. **សមាធិន្ទ្រីយ** សមាធិ ជាធំក្នុងការតាំងចិត្តមាំ
៥. **បញ្ញិន្ទ្រីយ** បញ្ញា ជាធំក្នុងសេចក្តីដឹងច្បាស់។

## **ពលៈ ៥**

១. **សទ្ធាពល** សទ្ធា ជាកម្លាំងក្នុងជំនឿ
២. **វីរិយពល** វីរិយៈ ជាកម្លាំងក្នុងសេចក្តីព្យាយាម
៣. **សតិពល** សតិ ជាកម្លាំងក្នុងការកម្ចាត់សេចក្តីវាយមាយ
៤. **សមាធិពល** សមាធិ ជាកម្លាំងក្នុងការតាំងចិត្តមាំ
៥. **បញ្ញាពល** បញ្ញា ជាកម្លាំងក្នុងការដឹងច្បាស់ ។

## **វិមុត្តិ៥**

១. **វិក្ខម្ភនវិមុត្តិ** ការរួចផុតចាកនីវរណៈដោយការចូលឈាន
២. **តទង្គវិមុត្តិ** រួចផុតចាកកិលេសនោះ ៗ ដោយអង្គធម៌

ដែលផ្ទុយគ្នា ។

**៣. សមុច្ឆេទវិមុត្តិ** រួចផុតចាកកិលេសដោយមគ្គញាណ ( លោកុត្តរមគ្គ )

**៤. បដិបស្សទ្ធិវិមុត្តិ** រួចផុតចាកកិលេសក្នុងខណៈផល ញាណ ( លោកុត្តរផល )

**៥. និស្សរណវិមុត្តិ** រួចផុតចាកកិលេសក្នុងខណៈបន្ទាប់ពី ផលញាណរៀងរហូតទៅ ។

## ពួកធម៌ ៦

## ចរិត ៦

**១. រាគចរិត** ប្រព្រឹត្តទៅតាមរាគៈ ចូលចិត្តស្អាត

**២. ទោសចរិត** ប្រព្រឹត្តទៅតាមទោសៈ ឆាប់ខឹង

**៣. មោហចរិត** ប្រព្រឹត្តទៅតាមមោហៈ ច្រើនភ្លេច

**៤. សទ្ធាចរិត** ប្រព្រឹត្តទៅតាមសទ្ធា ច្រើនឆាប់ជឿ

**៥. ពុទ្ធិចរិត** ប្រព្រឹត្តទៅតាមបញ្ញា គិតច្រើន ច្រើនជឿខ្លួនឯង

**៦. វិតក្កចរិត** ប្រព្រឹត្តទៅតាមវិតក្ក ត្រិះរិះច្រើន ច្រើនរាយមាយ។

## អាយតនៈខាងក្នុង ៦

**១. ចក្ខុ** ភ្នែក
**២. សោត** ត្រចៀក
**៣. ឃាន** ច្រមុះ
**៤. ជីវ្ហា** អណ្តាត
**៥. កាយ** កាយ
**៦. មនៈ** ចិត្ត ។

## អាយតនៈខាងក្រៅ ៦

**១. រូប** រូប
**២. សទ្ទ** សម្លេង
**៣. គន្ធ** ក្លិន
**៤. រស** រស
**៥. ផោដ្ឋព្វ** វត្ថុដែលប៉ះកាយ
**៦. ធម្ម ឬ ធម្មារម្មណ៍** អារម្មណ៍គឺធម៌ដែលប៉ះចិត្ត ។

## វិញ្ញាណ ៦

**១. ចក្ខុវិញ្ញាណ** សេចក្តីដឹងអារម្មណ៍ផ្លូវភ្នែក
**២. សោតវិញ្ញាណ** សេចក្តីដឹងអារម្មណ៍ផ្លូវត្រចៀក

៣. **ឃានវិញ្ញាណ** សេចក្តីដឹងអារម្មណ៍ផ្លូវច្រមុះ

៤. **ជីវ្ហាវិញ្ញាណ** សេចក្តីដឹងអារម្មណ៍ផ្លូវអណ្តាត

៥. **កាយវិញ្ញាណ** សេចក្តីដឹងអារម្មណ៍ផ្លូវកាយ

៦. **មនោវិញ្ញាណ** សេចក្តីដឹងអារម្មណ៍ផ្លូវចិត្ត ។

## ផស្សៈ ឬ សម្ផស្ស ៦

១. **ចក្ខុសម្ផស្ស** ការប្រជុំនៃធម៌ ៣ គឺ ភ្នែករូបចក្ខុវិញ្ញាណ

២. **សោតសម្ផស្ស** ការប្រជុំនៃធម៌ ៣ គឺ ត្រចៀកសម្លេង សោតវិញ្ញាណ

៣. **ឃានសម្ផស្ស** ការប្រជុំនៃធម៌ ៣ គឺ ច្រមុះក្លិនឃានវិញ្ញាណ

៤. **ជីវ្ហាសម្ផស្ស** ការប្រជុំនៃធម៌ ៣ គឺអណ្តាតរសជីវ្ហាវិញ្ញាណ

៥. **កាយសម្ផស្ស** ការប្រជុំនៃធម៌ ៣ គឺ កាយផោដ្ឋព្វកាយ វិញ្ញាណ

៦. **មនោសម្ផស្ស** ការប្រជុំនៃធម៌ ៣ គឺ ចិត្ត ធម្ម មនោ វិញ្ញាណ។

## វេទនា ៦

១. **ចក្ខុសម្ផស្សជា វេទនា** វេទនាកើតពី ចក្ខុសម្ផស្ស

២. **សោតសម្ផស្សជា វេទនា** វេទនាកើតពី សោតសម្ផស្ស

**៣. ឃានសម្ផស្សជា វេទនា** វេទនាកើតពី ឃានសម្ផស្ស
**៤. ជិវ្ហាសម្ផស្សជា វេទនា** វេទនាកើតពី ជីវ្ហាសម្ផស្ស
**៥. កាយសម្ផស្សជា វេទនា** វេទនាកើតពី កាយសម្ផស្ស
**៦. មនោសម្ផស្សជា វេទនា** វេទនាកើតពី មនោសម្ផស្ស

## សញ្ញា ៦

**១. រូបសញ្ញា** ចំណាំរូប ខ្មៅ ស...
**២. សទ្ទសញ្ញា** ចំណាំសម្លេង គ្រលរ គ្រលួច
**៣. គន្ធសញ្ញា** ចំណាំក្លិន ក្រអូប ស្អុយ
**៤. រសសញ្ញា** ចំណាំរស ផ្អែម ជូរ
**៥. ផោដ្ឋព្វសញ្ញា** ចំណាំផោដ្ឋព្វៈ រឹង ទន់
**៦. ធម្មសញ្ញា** ចំណាំធម៌ គួរស្រឡាញ់ ស្អប់ទៀងមិនទៀង។

## សញ្ចេតនា ៦ (ចេតនា ៦)

**១. រូបសញ្ចេតនា** តាំងចិត្ត ឬ ផ្តោតចិត្តក្នុងរូប
**២. សទ្ទសញ្ចេតនា** តាំងចិត្ត ឬ ផ្តោតចិត្តក្នុងសម្លេង
**៣. គន្ធសញ្ចេតនា** តាំងចិត្ត ឬ ផ្តោតចិត្តក្នុងក្លិន
**៤. រសសញ្ចេតនា** តាំងចិត្ត ឬ ផ្តោតចិត្តក្នុងរស
**៥. ផោដ្ឋព្វសញ្ចេតនា** តាំងចិត្ត ឬ ផ្តោតចិត្តក្នុងផោដ្ឋព្វៈ

**៦. ធម្មសញ្ចេតនា** តាំងចិត្ត ឬ ផ្ដោតចិត្តក្នុងធម្មារម្មណ៍

## តណ្ហា ៦

**១. រូបតណ្ហា** ចំណង់ក្នុងរូប
**២. សទ្ទតណ្ហា** ចំណង់ក្នុងសម្លេង
**៣.គន្ធតណ្ហា** ចំណង់ក្នុងក្លិន
**៤. រសតណ្ហា** ចំណង់ក្នុងរស
**៥. ផោដ្ឋព្វតណ្ហា** ចំណង់ក្នុងផោដ្ឋព្វៈ
**៦. ធម្មតណ្ហា** ចំណង់ក្នុងធម្មារម្មណ៍ ។

## អភិញ្ញា ៦

**១. ឥទ្ធិវិធិ** សំដែង ឫទ្ធិផ្សេងៗ បាន
**២. ទិព្វសោត** ត្រចៀកទិព្វ
**៣. ចេតោបរិយញ្ញាណ** ដឹងចិត្តអ្នកដទៃ
**៤. បុព្វេនិវាសានុស្សតិ** រឭកជាតិបាន
**៥. ទិព្វចក្ខុ** (ចុតូបបាតញ្ញាណ) ភ្នែកទិព្វ
**៦. អាសវក្ខយញ្ញាណ** ដឹងវិធីធ្វើឱ្យអស់អាសវៈ ។

## សតតវិហារ ៦

**ចក្ខុនា រូបំ ទិស្វា នេវ សុមនោ ហោតិ**
**ន ទុម្មនោ ឧបេក្ខកោ ច វិហរតិ សតោ**
**សម្បជានោ** ។ល។

១. ឃើញរូបដោយភ្នែក មិនសោមនស្ស មិនទោមនស្សតាំងចិត្តជាកណ្តាល មានសតិ សម្បជញ្ញ ។

២. ឮសម្លេងដោយត្រចៀក មិនសោមនស្ស មិនទោមនស្ស តាំងចិត្តជាកណ្តាល មានសតិ សម្បជញ្ញ ។

៣. ធុំក្លិនដោយច្រមុះ មិនសោមនស្ស មិនទោមនស្ស តាំងចិត្តជាកណ្តាល មានសតិ សម្បជញ្ញ ។

៤. ភ្លក់រសជាតិដោយអណ្តាត មិនសោមនស្ស មិនទោមនស្ស តាំងចិត្តជាកណ្តាល មានសតិ សម្បជញ្ញ ។

៥. ប៉ះផោដ្ឋព្វៈដោយកាយ មិនសោមនស្ស មិនទោមនស្ស តាំងចិត្តជាកណ្តាល មានសតិ សម្បជញ្ញ ។

៦. ដឹងធម្មារម្មណ៍ដោយចិត្ត មិនសោមនស្ស មិនទោមនស្ស តាំងចិត្តជាកណ្តាល មានសតិ សម្បជញ្ញ ។



# ធម៌ពួក ៧

## អរិយទ្រព្យ ៧

| | |
|---|---|
| **១. សទ្ធាធន** | ទ្រព្យ គឺ សទ្ធា |
| **២. សីលធន** | ទ្រព្យ គឺ សីល |
| **៣. ហិរិធន** | ទ្រព្យ គឺ សេចក្តីខ្មាសបាប |
| **៤. ឱត្តប្បធន** | ទ្រព្យ គឺ សេចក្តីខ្លាចបាប |
| **៥. សុតធន** | ទ្រព្យ គឺ ការស្តាប់ |
| **៦. ចាគធន** | ទ្រព្យ គឺ ការលះ |
| **៧. បញ្ញាធន** | ទ្រព្យ គឺ បញ្ញា។ |

## ពលៈ ៧

| | |
|---|---|
| **១. សទ្ធាពល** | កម្លាំង គឺ ជំនឿ |
| **២. វីរិយពល** | កម្លាំង គឺ សេចក្តីព្យាយាម |
| **៣. ហិរិពល** | កម្លាំង គឺ សេចក្តីខ្មាសបាប |
| **៤. ឱត្តប្បពល** | កម្លាំង គឺ សេចក្តីខ្លាចបាប |
| **៥. សតិពល** | កម្លាំង គឺ សេចក្តីនឹករឭក |
| **៦. សមាធិពល** | កម្លាំង គឺ ការតាំងចិត្តមាំ |
| **៧. បញ្ញាពល** | កម្លាំង គឺ សេចក្តីដឹងច្បាស់ ។ |

## អនុសយ កិលេសដេកត្រាំក្នុងចិត្ត ៧

១. **កាមរាគានុសយ** អនុស័យ គឺ សេចក្ដីត្រេអរក្នុងកាម
២. **បដិឃានុសយ** អនុស័យ គឺ សេចក្ដីថ្នាំងថ្នាក់ចិត្ត
៣. **ទិដ្ឋានុសយ** អនុស័យ គឺ ទិដ្ឋិយល់ឃើញខុស
៤. **វិចិកិច្ឆានុសយ** អនុស័យ គឺ សេចក្ដីសង្ស័យ
៥. **មានានុសយ** អនុស័យ គឺ មានះ
៦. **ភវរាគានុសយ** អនុស័យ គឺ សេចក្ដីត្រេកអរក្នុងភព
៧. **អវិជ្ជានុសយ** អនុស័យ គឺ អវិជ្ជា ។

## វិធីលះអាសវៈ ៧

១. លះដោយ **ទស្សនៈ** ការយល់ឃើញ
២. លះដោយ **សំវរៈ** ការសង្រួម
៣. លះដោយ **បដិសេវនៈ** ការសេព
៤. លះដោយ **អធិវាសនៈ** ការអត់ធន់
៥. លះដោយ **បរិវជ្ជនៈ** ការវៀរ
៦. លះដោយ **វិនោទនៈ** ការបន្ទោបង់
៧. លះដោយ **ភាវនា** ការអប់រំ ។

## កត្តានាំឱ្យសាបសូន្យនៃអ្នកបដិបត្តិធម៌ ៧

១. ចូលចិត្ត ធ្វើការងារ

២. ចូលចិត្ត និយាយ

៣. ចូលចិត្ត ដេក

៤. ចូលចិត្ត ការពពាក់ពពូន

៥. មិនសង្រួមឥន្ទ្រីយ៍ ៦

៦. មិនស្គាល់ប្រមាណក្នុងភោជន

៧. ចូលចិត្តធ្វើការងារដែលមិនមែនជាភារៈរបស់ខ្លួន ។

## អនុបុព្វបដិបទា បដិបត្តិតាមលំដាប់ ៧

១. រក្សាសីល

២. សង្រួមឥន្ទ្រីយ៍

៣. ស្គាល់ប្រមាណក្នុងភោជន

៤. ព្យាយាមភ្ញាក់រឮក

៥. មាន សតិសម្បជញ្ញៈ

៦. ធ្វើសមាធិ ជម្រះចិត្តចាកនីវរណៈ

៧. ស្ងាត់ចាកកាម ចាកអកុសល សម្រេចដល់ឈានទី ១ រហូតឈានទី ៤ ។

## ធម៌នាំឱ្យសម្រេចបដិសម្ភិទា ៧

១. កាលចិត្តខ្ជិលច្រអូស ដឹងច្បាស់

២. កាលចិត្តរួញរា ដឹងច្បាស់

៣. កាលចិត្តរាយមាយ ដឹងច្បាស់

៤. កាលវេទនា កើត រលត់ ដឹងច្បាស់

៥. កាលសញ្ញា កើត រលត់ ដឹងច្បាស់

៦. វិតក្ក កើត រលត់ ដឹងច្បាស់

៧. ធម៌ទាំងឡាយ ជាទីសប្បាយ មិនជាទីសប្បាយ ថោកទាប ប្រណិត ខ្មៅ ស ស្របគ្នា ឬទំនាស់គ្នា រៀនសូត្រ ធ្វើទុកក្នុងចិត្ត ចងចាំ ដឹងច្បាស់ល្អ នូវហេតុនោះ ដោយបញ្ញា៕

## ឧបាយកែងោកងុយ ៧

១. បើធ្វើទុកនូវសញ្ញាណាហើយងោកងុយ គប្បីធ្វើទុកសញ្ញានោះឱ្យច្រើនឡើងៗទៀត នឹងបាត់ងោកងុយ ។

២. បើនៅតែមិនបាត់ងោកងុយ គប្បីត្រិះរិះ រំពឹងពិចារណា ធម៌ដែលខ្លួនធ្លាប់ស្តាប់ ធ្លាប់រៀនសូត្រ ឱ្យច្រើនៗ នឹងបាត់ ងោកងុយ ។

៣. បើនៅមិនបាត់ងោកងុយ គប្បីស្វាធ្យាយ (សូត្រក្នុងចិត្ត ) នូវធម៌ដែលខ្លួនរៀនសូត្រហើយឱ្យច្រើនៗ នឹងបាត់ងោកងុយ ។

៤. បើនៅតែមិនបាត់ងោកងុយ   គប្បីយកដៃឆ្កៀលត្រចៀក
និងស្ទាបអង្អែលខ្លួន នឹងបាត់ងោកងុយ ។

៥. បើនៅតែមិនបាត់ងោកងុយ គប្បីក្រោកយកទឹកលប់មុខ
សម្លឹង មើលទិសផ្សេង ៗ នឹងបាត់ងោកងុយ ។

៦. បើនៅតែមិនបាត់ងោកងុយ   គប្បីធ្វើទុកក្នុងចិត្តនូវ
អាលោកសញ្ញា អធិដ្ឋានថា  ថ្ងៃយ៉ាងណា យប់ក៏យ៉ាងនោះ
យប់យ៉ាងណា ថ្ងៃក៏យ៉ាងនោះ នឹងបាត់ងោកងុយ ។

៧. បើនៅតែមិនបាត់ងោកងុយ   គប្បីដើរចង្ក្រមនឹងបាត់ងោក
ងុយ បើនៅតែមិនបាត់ងោកងុយទៀត គប្បីរកកន្លែងដេក
មានសតិសម្បជញ្ញៈធ្វើទុកក្នុងចិត្ត នូវឧដ្ឋានសញ្ញា ថានឹង
ក្រោកឡើងបដិបត្តិធម៌ទៀត ។

## សមាធិបរិក្ខារ ៧

**១. សម្មាទិដ្ឋិ**
**២. សម្មាសង្កប្បោ**
**៣. សម្មាវាចា**
**៤. សម្មាកម្មន្តោ**
**៥. សម្មាអាជីវោ**
**៦. សម្មាវាយាមោ**
**៧. សម្មាសតិ ៕**



## ពោជ្ឈង្គ ៧

**១. សតិ** សេចក្ដីនឹករឭក
**២. ធម្មវិចយ** ការជ្រើសរើសធម៌
**៣. វីរិយ** សេចក្ដីព្យាយាម
**៤. បីតិ** សេចក្ដីឆ្អែតចិត្ត
**៥. បស្សទ្ធិ** សេចក្ដីស្ងប់កាយ ស្ងប់ចិត្ត
**៦. សមាធិ** ចិត្តតាំងមាំ
**៧. ឧបេក្ខា** ចិត្តជាកណ្ដាល ៕

## វិសុទ្ធិ ៧

**១. សីលវិសុទ្ធិ** សេចក្ដីបរិសុទ្ធិនៃសីល
**២. ចិត្តវិសុទ្ធិ** សេចក្ដីបរិសុទ្ធិនៃចិត្ត
**៣. ទិដ្ឋិវិសុទ្ធិ** សេចក្ដីបរិសុទ្ធិនៃការឃើញ
**៤. កង្ខាវិតរណវិសុទ្ធិ** សេចក្ដីបរិសុទ្ធិនៃញាណ ជាគ្រឿងកន្លងផុតសេចក្ដីសង្ស័យ ។
**៥. មគ្គាមគ្គញាណទស្សនវិសុទ្ធិ** សេចក្ដីបរិសុទ្ធិនៃញាណ ជាគ្រឿងឃើញថា នេះជាផ្លូវ នេះមិនមែនជាផ្លូវ ។
**៦. បដិបទាញាណទស្សនវិសុទ្ធិ** សេចក្ដីបរិសុទ្ធិនៃញាណ ជាគ្រឿងឃើញបដិបទា ដែលនឹងឱ្យអរិយមគ្គកើតឡើង ។

**៧. ញាណទស្សនវិសុទ្ធិ** សេចក្តីបរិសុទ្ធិនៃញាណទស្សនៈ គឺ
ឃើញមគ្គទាំង ៤ ។

## ធម៌ញុំាងចិត្តឱ្យប្រព្រឹត្តទៅក្នុងអំណាច ៧

**១. សមាធិកុសលោ** ឈ្លាសក្នុងសមាធិ
**២. សមាបត្តិកុសលោ** ឈ្លាសក្នុងការចូលសមាធិ
**៣. ឋិតិកុសលោ** ឈ្លាសក្នុងការតាំងនៅនៃសមាធិ
**៤. វុដ្ឋានកុសលោ** ឈ្លាសក្នុងការចេញចាកសមាធិ
**៥. កល្លិតកុសលោ** ឈ្លាសក្នុងការចែករំលែកសមាធិ
**៦. គោចរកុសលោ** ឈ្លាសក្នុងគោចរ (អារម្មណ៍)នៃសមាធិ
**៧. អភិនីហារកុសលោ** ឈ្លាសក្នុងការនាំមកនូវ
សមាធិ៕

## ពួកធម៌ ៨

## អរិយបុគ្គល ៨ ពួក

**១. សោតាបន្ន** អ្នកសម្រេចសោតាបត្តិផលហើយ
២. អ្នកបដិបត្តិ កំពុងនៅក្នុង **សោតាបត្តិមគ្គ**
**៣. សកទាគាមី** អ្នកសម្រេចសកទាគាមិផលហើយ

៤. អ្នកបដិបត្តិ កំពុងនៅក្នុង **សកទាគាមិមគ្គ**
៥. **អនាគាមី** អ្នកសម្រេចអនាគាមិផលហើយ
៦. អ្នកបដិបត្តិ កំពុងនៅក្នុង **អនាគាមិមគ្គ**
៧. **អរហន្ត** អ្នកសម្រេចអរហត្តផលហើយ
៨.អ្នកបដិបត្តិ កំពុងនៅក្នុង **អរហត្តមគ្គ** ។

## អវិជ្ជា ៨

១. **ទុក្ខេ អញ្ញាណំ** មិនដឹងច្បាស់ទុក្ខ
២. **ទុក្ខសមុទយេ អញ្ញាណំ** មិនដឹងច្បាស់ហេតុឱ្យទុក្ខកើត
៣. **ទុក្ខនិរោធេ អញ្ញាណំ** មិនដឹងច្បាស់ការ រលត់ទុក្ខ
៤. **ទុក្ខនិរោធគាមិនិយា បដិបទាយ អញ្ញាណំ** មិនដឹងច្បាស់បដិបទាឱ្យដល់នូវការរលត់ទុក្ខ
៥. **បុព្វន្តេ អញ្ញាណំ** មិនដឹងច្បាស់អតីត
៦. **អបរន្តេ អញ្ញាណំ** មិនដឹងច្បាស់អនាគត
៧. **បុព្វន្តាបរន្តេ អញ្ញាណំ** មិនដឹងច្បាស់អតីតនិងអនាគត
៨. **ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណំ** មិនដឹងច្បាស់ធម៌ទាំងឡាយដែលអាស្រ័យគ្នាកើតមានឡើង តាមគោល **ឥទប្បច្ចយតា** ។



## **វិជ្ជា ៨**

| | |
|---|---|
| **១. វិបស្សនាញាណ** | ញាណក្នុងវិបស្សនា |
| **២. មនោមយិទ្ធិ** | ឫទ្ធិសម្រេចដោយចិត្ត |
| **៣. ឥទ្ធិវិធិ** | សម្តែងឫទ្ធិផ្សេង ៗ បាន |
| **៤. ទិព្វសោត** | ត្រចៀកទិព្វ |
| **៥. ចេតោបរិយញាណ** | ដឹងចិត្តអ្នកដទៃ |
| **៦. បុព្វេនិវាសានុស្សតិញាណ** | រឭកជាតិបាន |
| **៧. ទិព្វចក្ខុ** (ចុតូបបាតញាណ ) | ភ្នែកទិព្វ |
| **៨. អាសវក្ខយញាណ** | ញាណក្នុងការធ្វើឱ្យអស់នូវអាសវៈ។ |

## **អដ្ឋង្គិកមគ្គ** ផ្លូវប្រកបដោយអង្គ ៨

| | |
|---|---|
| **១. សម្មាទិដ្ឋិ** | ការយល់ឃើញត្រូវ |
| **២. សម្មាសង្កប្បោ** | សេចក្តីត្រិះរិះត្រូវ |
| **៣. សម្មាវាចា** | ពាក្យសំដីត្រូវ |
| **៤. សម្មាកម្មន្តោ** | ការងារត្រូវ |
| **៥. សម្មាអាជីវោ** | ការចិញ្ចឹមជីវិតត្រូវ |
| **៦. សម្មាវាយាមោ** | សេចក្តីព្យាយាមត្រូវ |
| **៧. សម្មាសតិ** | ការរឭកត្រូវ |

**៨. សម្មាសមាធិ** ចិត្តតាំងមាំត្រូវ ។

## ឈាន ៨ ឬ សមាបត្តិ ៨

រូបជ្ឈាន ៤ អរូបជ្ឈាន ៤ ហៅថា ឈាន ៨ ឬ សមាបត្តិ ៨ ក៏បាន។

## កត្តានាំឱ្យសាបសូន្យ ដល់អ្នកបដិបត្តិធម៌ ៨

**១. កម្មារាមតា** ចូលចិត្តធ្វើការងារ

**២. ភស្សារាមតា** ចូលចិត្តនិយាយ

**៣. និទ្ទារាមតា** ចូលចិត្តដេក

**៤. សង្គណិការាមតា** ចូលចិត្តពពាក់ពពូន

**៥. ឥន្ទ្រិយេសុ អគុត្តទ្វារតា** មិនសង្រួមក្នុងឥន្ទ្រិយ ៦

**៦. ភោជនេ អមត្តញ្ញុតា** មិនស្គាល់ប្រមាណក្នុងភោជន

**៧. សំសគ្គារាមតា** ត្រេកអរក្នុងការជាប់ជំពាក់

**៨. បបញ្ចារាមតា** ត្រេកអរក្នុងធម៌ជាគ្រឿងយឺតយូរ ។

## ធម៌ជាបច្ច័យ តៗ គ្នា ៨

**១. សតិសម្បជញ្ញៈ** ជាបច្ច័យឱ្យកើត ហិរិឱត្តប្បៈ

**២. ហិរិឱត្តប្បៈ** ជាបច្ច័យឱ្យកើត ឥន្ទ្រិយ៍សំវរៈ

**៣. ឥន្ទ្រីយសំវរៈ** ជាបច្ច័យឱ្យកើត សីល

**៤. សីល** ជាបច្ច័យឱ្យកើត សមាធិ
**៥. សមាធិ** ជាបច្ច័យឱ្យកើត យថាភូតញ្ញាណទស្សនៈ
**៦. យថាភូតញ្ញាណទស្សនៈ** ជាបច្ច័យឱ្យកើត និព្វិទាវិរាគ
**៧. និព្វិទាវិរាគ** ជាបច្ច័យឱ្យកើត វិមុត្តិញ្ញាណទស្សនៈ
**៨. វិមុត្តិ** ជាទីបំផុតនៃការបដិបត្តិធម៌ ។

## វិមោក្ខ ៨

បុគ្គលមានរូបជ្ឈាន រមែងឃើញនូវរូបគឺកសិណទាំងឡាយ (មាននីលកសិណជាដើម) នេះជាវិមោក្ខទី ១ ។ បុគ្គលពួកមួយមិនមានសេចក្តីសំគាល់នូវរូបខាងក្នុង (មានសក់ជាដើម) រមែងឃើញនូវរូបខាងក្រៅទាំងឡាយគឺកសិណ (មាននីលកសិណជាដើម) នេះជាវិមោក្ខទី ២ ។ បុគ្គលមានចិត្តចុះស៊ប់ថា វណ្ណកសិណដ៏បរិសុទ្ធ នេះជាវិមោក្ខទី ៣ ។ ព្រោះកន្លងនូវសញ្ញាដោយប្រការទាំងពួង ដល់នូវសេចក្តីវិនាសនៃបដិឃសញ្ញា មិនបានធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា បានដល់នូវអាកាសានញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថាអាកាសមិនមានទីបំផុតដូច្នេះនេះជាវិមោក្ខទី ៤ ។ ព្រោះកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង បានដល់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុតដូច្នេះ នេះជាវិមោក្ខទី ៥ ។ ព្រោះកន្លងនូវវិញ្ញាណ

ញ្ញាយតនជ្ឈាន ដោយប្រការទាំងពួងបានដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អ្វីតិចតួចក៏មិនមានដូច្នេះ នេះជាវិមោក្ខទី ៦ ។ ព្រោះកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង បានដល់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាននេះជាវិមោក្ខទី ៧ ។ ព្រោះកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង បានដល់នូវសញ្ញាវេទយិតនិរោធ ( សេចក្ដីរលត់នៃសញ្ញា និង វេទនា ) នេះជាវិមោក្ខទី ៨ ។

## **អភិភាយតនៈ ៨**

បុគ្គលពួកមួយ មានសេចក្ដីសំគាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបមានប្រមាណតិច មានសម្បុរល្អ ឬ សម្បុរអាក្រក់ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្ដីសំគាល់យ៉ាងនេះថា អាត្មាអញដឹងអាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ១ ។ បុគ្គលពួកមួយ មានសេចក្ដីសំគាល់នូវរូបខាងក្នុងឃើញនូវរូបខាងក្រៅ ជារូបមានប្រមាណច្រើន មានសម្បុរល្អ ឬ សម្បុរអាក្រក់ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្ដីសំគាល់យ៉ាងនេះថា អាត្មាដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ២ ។ បុគ្គលពួកមួយ មិនមានសេចក្ដីសំគាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបមានប្រមាណតិចមានសម្បុរល្អ ឬ សម្បុរអាក្រក់ គ្របសង្កត់

នូវរូបទាំងនោះ ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ៣ ។ បុគ្គលពួកមួយមិនមានសេចក្តីសំគាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅជារូបមាន ប្រមាណច្រើន មានសម្បុរល្អ ឬ សម្បុរអាក្រក់គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ៤ ។ បុគ្គលពួកមួយមិនមានសេចក្តីសំគាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅជារូបខៀវ មានសម្បុរខៀវ ជាទីចង្អុលប្រាប់ថា នេះមានសម្បុរខៀវ មានពន្លឺខៀវ គ្របសង្កត់នូវរូបទាំងនោះហើយ មានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ៥ ។ បុគ្គលពួកមួយមិនមានសេចក្តីសំគាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅជារូបលឿង មានសម្បុរលឿងជាទីចង្អុលប្រាប់ថា នេះមានសម្បុរលឿង មានពន្លឺលឿង គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ៦ ។ បុគ្គលពួកមួយ មិនមានសេចក្តីសំគាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅជារូបក្រហម មានសម្បុរក្រហម ជាទីចង្អុលប្រាប់ថានេះមានសម្បុរក្រហម មានពន្លឺក្រហម គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយ

តនៈទី ៧ ។ បុគ្គលពួកមួយ មិនមានសេចក្ដីសំគាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបស មានសម្បុរស ជាទីចង្អុលប្រាប់ថា នេះជាសម្បុរ ស មានពន្លឺ ស គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្ដីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ៨ ៕

## ធម៌ពួក ៩

**អនុបុព្វវិហារ** ធម៌ជាគ្រឿងនៅតាមលំដាប់ ៩ រូបជ្ឈាន ៤ អរូបជ្ឈាន ៤ និង សញ្ញាវេទយិតនិរោធ ១ ។

**អនុបុព្វនិរោធ** ធម៌ជាគ្រឿងរលត់តាមលំដាប់ ៩

១. ចូល បឋមឈាន កាមសញ្ញា រលត់
២. ចូល ទុតិយឈាន វិតក្ក វិចារ រលត់
៣. ចូល តតិយឈាន បីតិ រលត់
៤. ចូល ចតុត្ថឈាន អស្សាសបស្សាស រលត់
៥. ចូល អាកាសានញ្ចាយតនឈាន រូបសញ្ញា រលត់
៦. ចូល វិញ្ញាណញ្ចាយតនឈាន អាកាសានញ្ចាយតនសញ្ញា រលត់
៧. ចូល អាកិញ្ចញ្ញាយតនឈាន វិញ្ញាណញ្ចាយតនសញ្ញា រលត់

៨. ចូល នេវសញ្ញានាសញ្ញាយតនឈាន អាកិញ្ចញ្ញាយតនសញ្ញា រលត់

៩. ចូល សញ្ញាវេទយិតនិរោធ សញ្ញា និង វេទនា រលត់ ។

## **ធម៌ដែលគួរចំរើន ៩**

**១. សីលវិសុទ្ធិ,  ២. ចិត្តវិសុទ្ធិ,  ៣. ទិដ្ឋិវិសុទ្ធិ**
**៤. កង្ខាវិតរណវិសុទ្ធិ,  ៥. មគ្គាមគ្គញាណទស្សនវិសុទ្ធិ**
**៦. បដិបទាញាណទស្សនវិសុទ្ធិ,  ៧. ញាណទស្សនវិសុទ្ធិ**
**៨. បញ្ញាវិសុទ្ធិ  ៩. វិមុត្តិវិសុទ្ធិ ។**

## **ធម៌ដែលត្រូវលះ ៩**
## **មានតណ្ហាជាមូល**

១. អាស្រ័យ  តណ្ហា  កើត បរិយេសនា  ការស្វែងរក

២. អាស្រ័យ  បរិយេសនា  កើត  លាភ  ការបាន

៣. អាស្រ័យ  លាភ  កើត  វិនិច្ឆយោ  សេចក្តីត្រិះរិះ វិនិច្ឆ័យ

៤. អាស្រ័យ  វិនិច្ឆយ  កើត  ឆន្ទរាគ  សេចក្តីពេញចិត្ត

៥. អាស្រ័យ  ឆន្ទរាគ  កើត  អជ្ឈោសាន  សេចក្តីជឿស៊ប់

៦. អាស្រ័យ  អជ្ឈោសាន  កើត  បរិគ្គហ  ការហួងហែង

៧. អាស្រ័យ  បរិគ្គហ  កើត  មច្ឆរិយ  សេចក្តីកំណាញ់

៨. អាស្រ័យ  មច្ឆរិយ  កើត  អារក្ខ  ការរក្សា
៩. អាស្រ័យ  អារក្ខ  កើត  អកុសល  បាបអកុសល  ជាច្រើន គឺ
     ការកាន់ ដំបង គ្រឿងសស្ត្រាវុធ ឈ្លោះទាស់ទែង ។ ល ។

## ធម៌ដែលត្រូវចំរើន ៩
## មាន យោនិសោមនសិការ ជាមូល

១. អាស្រ័យយោនិសោមនសិការ  កើត  បាមោជ្ជ សេចក្តីរីករាយ
២. អាស្រ័យ បាមោជ្ជ     កើត បីតិ    សេចក្តីត្រេកអរឆ្អែតចិត្ត
៣. អាស្រ័យ     បីតិ  កើត  កាយបស្សទ្ធិ  សេចក្តីស្ងប់កាយ
៤. អាស្រ័យ  កាយបស្សទ្ធិ  កើត  សុខ  សេចក្តីសុខចិត្ត
៥. អាស្រ័យ  សុខ  កើត  សមាធិ  ការតាំងចិត្តមាំ
៦. អាស្រ័យ   សមាធិ  កើត  យថាភូតញាណ  សេចក្តីដឹងច្បាស់
     តាមការពិត
៧. អាស្រ័យ  យថាភូតញ្ញាណ កើត  និព្វិទា សេចក្តីនឿយណាយ
៨. អាស្រ័យ  និព្វិទា  កើត  វិរាគ  សេចក្តីប្រាសចាកតម្រេក
៩. អាស្រ័យ  វិរាគ  កើត  វិមុត្តិ  ការរួចផុត ។



## វិបស្សនាញាណ ៩

១. **ឧទយព្វយញាណ** បញ្ញាដឹងច្បាស់នូវការកើត និង ការរលត់នៃនាមរូប ។

២. **ភង្គញាណ** បញ្ញាដឹងច្បាស់នូវការរលត់នៃនាមរូប ។

៣. **ភយតូបដ្ឋានញាណ** បញ្ញាដឹងច្បាស់នូវនាមរូបគួរ ឱ្យភ័យខ្លាច ។

៤. **អាទីនវញាណ** បញ្ញាដឹងច្បាស់នូវទោសនៃនាមរូប ។

៥. **និព្វិទាញាណ** បញ្ញាដឹងច្បាស់នូវនាមរូប គួរឱ្យនឿយណាយ ។

៦. **មុញ្ចិតុកម្យតាញាណ** បញ្ញាដឹងច្បាស់នូវនាមរូបហើយ ប្រាថ្នាឱ្យរួចផុតពីនាមរូប ។

៧. **បដិសង្ខាញាណ** បញ្ញាដឹងច្បាស់នូវនាមរូបហើយគិតត្រិះរិះ រកឧបាយរំដោះឱ្យផុតពីនាមរូប ។

៨. **សង្ខារុបេក្ខាញាណ** បញ្ញាដឹងច្បាស់នូវនាមរូប មិន ស្រឡាញ់ មិនស្អប់ ហើយតាំងចិត្តជាកណ្ដាល ។

៩. **អនុលោមញាណ** បញ្ញាដឹងច្បាស់នូវនាមរូប ហើយអនុលោមតាមញាណខាងដើមផង អនុលោមតាមពោធិបក្ខិយធម៌ផង ជាហេតុឱ្យឃើញអរិយសច្ចទាំង ៤ ៕

## ព្រះនព្វលោកុត្តរធម៌ ៩ គឺ

មគ្គ ៤, ផល ៤, និព្វាន ១។

## ធម៌ពួក ១០

### បារមី ១០

១. **ទាន** ការឱ្យទាន ២. **សីល** ការរក្សាសីលធ្វើកាយវាចាឱ្យរៀបរយ ៣. **នេក្ខម្ម** ការចេញបួស ៤. **បញ្ញា** ប្រាជ្ញា ៥.**វីរិយ** សេចក្តីព្យាយាម ៦.**ខន្តិ** សេចក្តីអត់ធន់ ៧. **សច្ច** សេចក្តីពិតត្រង់ ៨. **អធិដ្ឋាន** សេចក្តីសម្រេចចិត្តច្បាស់លាស់ ៩. **មេត្តា** សេចក្តីស្រឡាញ់រាប់អាន ១០. **ឧបេក្ខា** ការតាំងចិត្តជាកណ្តាល ។ ចែកទៅជា ៣០ គឺ បារមី ១០, ឧបបារមី ១០ , បរមត្ថបារមី ១០ ។

### បលិពោធ ១០

១. **អាវាស** ទីកន្លែង ២. **កុល** ត្រកូល ៣. **លាភ** លាភសក្ការៈ ៤. **គណ** ពួកក្រុម ៥. **កម្ម** ការងារ ៦. **ញាតិ** ញាតិសន្តាន ៧. **អាពាធ** ជម្ងឺតំកាត់ ៨. **គន្ថ** ការសិក្សារៀនសូត្រ ៩. **ឥទ្ធិ** ការសម្តែងឫទ្ធិ ១០. **អទ្ធាន** ការធ្វើដំណើរ ។

## វិបស្សនូបក្កិលេស ១០

១. **ឳភាសោ** ពន្លឺ ២. **ញាណ** សេចក្ដីដឹង ៣. **បីតិ** សេចក្ដីឆ្អែតចិត្ត ៤. **បស្សទ្ធិ** សេចក្ដីស្ងប់ត្រជាក់ ៥. **សុខ** សេចក្ដីសុខចិត្ត ៦. **អធិមោក្ខ** ជំនឿខ្លាំង ៧. **បគ្គាហ** សេចក្ដីព្យាយាម ៨. **ឧបដ្ឋាន** សតិចាស់ក្លាច្បាស់ ៩. **ឧបេក្ខា** ចិត្តជាកណ្ដាល ១០. **និកន្តិ** សេចក្ដីពេញចិត្ត ។

## កិលេស ១០

១. **លោភ** សេចក្ដីលោភលន់ ២. **ទោស** សេចក្ដីក្រោធខឹង ៣. **មោហ** សេចក្ដីវង្វេង ៤. **មានៈ** សេចក្ដីប្រកាន់ ៥. **ទិដ្ឋិ** សេចក្ដីយល់ខុស ៦. **វិចិកិច្ឆា** សេចក្ដីសង្ស័យ ៧. **ថីន** សេចក្ដីធុញ ៨. **ឧទ្ធច្ច** សេចក្ដីអណ្ដែតអណ្ដូង ៩. **អហិរិក** សេចក្ដីមិនខ្មាសបាប ១០.**អនោត្តប្ប** សេចក្ដីមិនខ្លាចបាប ។

## សំយោជនៈ ១០ គឺៈ

**ឱរម្ភាគិយសំយោជនៈ** ៥ និង **ឧទ្ធម្ភាគីយសំយោជនៈ** ៥ ត្រូវជា ១០ បានរៀបរៀងទុកហើយ ក្នុងធម៌ ពួក ៥ ។

## **វិបស្សនាញាណ ១០**

ក្នុងបាលីដើម វិបស្សនាញាណ មាន ៩ ដូចបានរៀបរៀងទុកក្នុងធម៌ពួក ៩ ស្រាប់ហើយ ។ ប៉ុន្តែក្នុងគម្ពីរ អភិធម្មត្ថសង្គហៈ បន្ថែមសម្មសនញាណ ការពិចារណា នាមរូបជាព្រះត្រៃលក្ខណ៍ ១ ទៀត ត្រូវជា ១០ ហោង ។

## **អាហាររបស់តវតណ្ហា ១០**

១. **អសប្បុរិសសំសេវ** ការមិនសេពគប់សប្បុរស ជាអាហាររបស់ អសទ្ធម្មស្សវនៈ ការមិនស្តាប់ព្រះសទ្ធម្ម ។

២. **អសទ្ធម្មស្សវនៈ** ជាអាហាររបស់ អសទ្ធិយ សេចក្តីមិនជឿ។

៣. **អសទ្ធិយៈ** ជាអាហាររបស់ អយោនិសោមនសិការៈ ។

៤. **អយោនិសោមនសិការ** ជាអាហាររបស់ អសតាសម្បជញ្ញៈ ការមិនមានសតិ សម្បជញ្ញៈ ។

៥. **អសតាសម្បជញ្ញៈ** ជាអាហាររបស់ ឥន្ទ្រីយាសំវរ ការមិនសង្រួមឥន្ទ្រីយ៍ ។

៦. **ឥន្ទ្រីយាសំវរ** ជាអាហាររបស់ ទុច្ចរិត ។

៧. **ទុច្ចរិត** ជាអាហាររបស់ នីវរណៈ

៨. **នីវរណៈ** ជាអាហាររបស់ អវិជ្ជា

**៩. អវិជ្ជា** ជាអាហាររបស់ ភវតណ្ហា
**១០. ភវតណ្ហា** ជាអាហាររបស់ អវិជ្ជា មិនមានទីបំផុតខាងដើមទេ ។

## អាហាររបស់ វិជ្ជា និង វិមុត្តិ ១០

**១. សប្បុរិសសំសេវៈ** ការសេពគប់សប្បុរស ជាអាហាររបស់ សទ្ធម្មស្សវនៈ ការស្តាប់ព្រះសទ្ធម្ម
**២. សទ្ធម្មស្សវនៈ** ជាអាហាររបស់ សទ្ធា
**៣. សទ្ធា** ជាអាហាររបស់ យោនិសោមនសិការ
**៤. យោនិសោមនសិការ** ជាអាហាររបស់ សតិសម្បជញ្ញៈ
**៥. សតិសម្បជញ្ញៈ** ជាអាហាររបស់ឥន្ទ្រីយសំវរៈ
**៦. ឥន្ទ្រីយសំវរៈ** ជាអាហាររបស់ សុចរិត
**៧. សុចរិត** ជាអាហាររបស់ សតិប្បដ្ឋាន
**៨. សតិប្បដ្ឋាន** ជាអាហាររបស់ ពោជ្ឈង្គ
**៩. ពោជ្ឈង្គ** ជាអាហាររបស់ វិជ្ជា និង វិមុត្តិ
**១០. វិជ្ជា និង វិមុត្តិ** ជាផលទីបំផុត ។

## សញ្ញា ១០

**១. អនិច្ចសញ្ញា** សំគាល់ថាមិនទៀង **២. អនត្តសញ្ញា** សំគាល់

ថាមិនមានអត្តា ៣. **អសុភសញ្ញា** សំគាល់ថាមិនស្អាត ៤. **អាទីនវសញ្ញា** សំគាល់ថាមានទោសច្រើន ៥. **បហានសញ្ញា** សំគាល់ថាគួរលះបង់ ៦. **វិរាគសញ្ញា** សំគាល់ថា ប្រាសចាកតម្រេក ៧. **និរោធសញ្ញា** សំគាល់ថារលត់ ៨. **សព្វ លោកេ អនភិរតសញ្ញា** សំគាល់ថា មិនគួរត្រេកអរក្នុងលោក ទាំងពួង ៩. **សព្វសង្ខារេសុ អនិច្ចសញ្ញា** សំគាល់ថាមិនគួរប្រាថ្នាក្នុងសង្ខារទាំងពួង ១០. **អានាបានស្សតិ** មានសតិដក ដង្ហើមចេញចូល ។

## ទសពិធរាជធម៌ ១០

១. **ទាន** ការឱ្យទាន, ២. **សីល** ការរក្សាសីល៥, ៣. **បរិច្ចាគ** ការបរិច្ចាគទ្រព្យ, ៤. **អាជ្ជវ** សេចក្ដីស្មោះត្រង់ ៥. **មទ្ទវៈ** សេចក្ដីសុភាពទន់ភ្លន់, ៦. **តបៈ** ការរក្សាឧបោសថដុតកិលេសផ្សេង ៗ និង ដុតអ្នកធ្វើខុសឱ្យទទួលទោសតាមច្បាប់ ៧. **អក្កោធន** ការមិនក្រេវក្រោធ, ៨. **អវិហឹសា** ការមិនបៀតបៀន, ៩. **ខន្តិ** សេចក្ដីអត់ធន់, ១០. **អវិរោធន** ការមិនបំពានលើច្បាប់ ។

## កសិណ ១០

១. **បឋវីកសិណ** សម្លឹងដី

២. **អាបោកសិណ** សម្លឹងទឹក

**៣. តេជោកសិណ** សម្លឹងភ្លើង
**៤. វាយោកសិណ** សម្លឹងខ្យល់
បួននេះហៅថា ភូតកសិណ
**៥. នីលកសិណ** សម្លឹងពណ៌ខៀវ
**៦. បីតកសិណ** សម្លឹងពណ៌លឿង
**៧. លោហិតកសិណ** សម្លឹងពណ៌ក្រហម
**៨. ឱទាតកសិណ** សម្លឹងពណ៌ស
បួននេះហៅថា វណ្ណកសិណ
**៩. អាលោកកសិណ** សម្លឹងពន្លឺ
**១០. អាកាសកសិណ** សម្លឹងអាកាស
ពីរនេះ ជាកសិណផ្សេង ៗ ។

## អសុភ ១០

**១. ឧទ្ធុមាតកអសុភ** សាកសពហើមប៉ោង
**២. វិនីលកអសុភ** សាកសពហើមពណ៌ខៀវ
**៣. វិបុព្វកអសុភ** សាកសពមានខ្ទុះហូរចេញ
**៤.វិច្ឆិទ្ទកអសុភ** សាកសពដាច់ពាក់កណ្ដាលខ្លួន
**៥. វិក្ខាយិតកអសុភ** សាកសពដែលសត្វខាំកកេរស៊ី
**៦. វិក្ខិត្តកអសុភ** សាកសពមានដៃជើងដាច់ជាកំណាត់

**៧. ហតវិក្ខិត្តកអសុភ** សាកសពដែលគេកាប់សាប់មានស្នាមរវាម

**៨. លោហិតកអសុភ** សាកសពមានឈាមហូរស្រោច

**៩. បុឡុវកអសុភ** សាកសពមានដង្កូវ

**១០. អដ្ឋិកអសុភ** សាកសពមានតែរាងឆ្អឹង ។

## អនុស្សតិ ១០

**១. ពុទ្ធានុស្សតិ** រឭកគុណព្រះពុទ្ធ

**២. ធម្មានុស្សតិ** រឭកគុណព្រះធម៌

**៣. សង្ឃានុស្សតិ** រឭកគុណព្រះសង្ឃ

**៤. សីលានុស្សតិ** រឭកគុណសីលរបស់ខ្លួន

**៥. ចាគានុស្សតិ** រឭកគុណទានដែលខ្លួនបានបរិច្ចាគ

**៦. ទេវតានុស្សតិ** រឭកគុណធម៌របស់ទេវតា

**៧. មរណានុស្សតិ** រឭកគុណសេចក្ដីស្លាប់

**៨. កាយគតានុស្សតិ** រឭកគុណកាយមានសក់ជាដើម

**៩. អានាបានស្សតិ** រឭកគុណខ្យល់ដកដង្ហើមចេញចូល

**១០. ឧបសមានុស្សតិ** រឭកគុណព្រះនិព្វាន ។

កសិណ ១០, អសុភ១០, អនុស្សតិ១០, ព្រហ្មវិហារ ៤, អាហារេបដិកូលសញ្ញា ១, ចតុធាតុវវត្ថាន ១ , អរូប ៤, មានអាកាសាន

ញ្ញាយតនៈជាដើម រួមជា ៤០ ជាអារម្មណ៍របស់សមថកម្មដ្ឋាន។

## ធម៌ពួក ១១

## អានិសង្សការចម្រើនមេត្តា ១១

**១. សុខំ សុបតិ** ដេកលក់ស្រួល

**២. សុខំ បដិពុជ្ឈតិ** ភ្ញាក់ឡើងស្រួល

**៣. ន បាបកំ សុបិនំ បស្សតិ** មិនយល់សប្តិអាក្រក់

**៤. មនុស្សានំ បិយោ ហោតិ** ជាទីស្រឡាញ់របស់ពួកមនុស្ស

**៥. អមនុស្សានំ បិយោ ហោតិ** ជាទីស្រឡាញ់របស់ពួកអមនុស្ស

**៦. ទេវតា រក្ខន្តិ** ទេវតាតែងថែរក្សា

**៧. នាស្ស អគ្គិ វា វិសំ វា សត្ថំ វា កមតិ** រមែងឆ្លងផុតពីភ្លើង ពិសពុល ឬ សស្ត្រាវុធ

**៨. តុវដំ ចិត្តំ សមាធិយតិ** ចិត្តឆាប់តាំងមាំជាសមាធិ

**៩. មុខវណ្ណោ វិប្បសីទតិ** សម្បុរមុខស្រស់បស់

**១០. អសម្មុឡ្ហោ កាលំ ករោតិ** ពេលស្លាប់មិនវង្វេង

**១១. ឧត្តរឹ អប្បដិវិជ្ឈន្តោ ព្រហ្មលោកូបគោ ហោតិ** បើមិនទាន់បានចាក់ធ្លុះធម៌ដ៏ក្រៃលែង រមែងកើតក្នុងព្រហ្មលោក។

# ធម៌ពួក ១២

## ទុក្ខ ១២ ករ

**១. ជាតិទុក្ខ** ការកើតជាទុក្ខ

**២. ជរាទុក្ខ** ការចាស់គ្រាំគ្រាជាទុក្ខ

**៣. មរណទុក្ខ** សេចក្តីស្លាប់ជាទុក្ខ

**៤. សោកទុក្ខ** សេចក្តីក្រៀមក្រំជាទុក្ខ

**៥. បរិទេវទុក្ខ** សេចក្តីខ្សឹកខ្សួលជាទុក្ខ

**៦. ទុក្ខទុក្ខ** សេចក្តីលំបាកកាយជាទុក្ខ

**៧. ទោមនស្សទុក្ខ** ការអាក់អន់ចិត្តជាទុក្ខ

**៨. ឧបាយាសទុក្ខ** ការតានតឹងចិត្តជាទុក្ខ

**៩. អប្បិយេហិ សម្បយោគទុក្ខ** ការជួបប្រសព្វដោយ សត្វ និង សង្ខារ មិនជាទីស្រឡាញ់ទាំងឡាយ ជាទុក្ខ

**១០. បិយេហិ វិប្បយោគទុក្ខ** ការព្រាត់ប្រាសចាកសត្វ និង សង្ខារ ជាទីស្រឡាញ់ទាំងឡាយ ជាទុក្ខ

**១១. យម្បិច្ឆំ ន លភតិ តម្បិទុក្ខ** ប្រាថ្នារបស់ណាមិនបាន នោះក៏ជាទុក្ខ

**១២. សង្ខិត្តេន បញ្ចុបាទានក្ខន្ធទុក្ខ** ពោលដោយ បំប្រួញ ឧបាទានក្ខន្ធទាំង ៥ ជាទុក្ខ ។

## អាយតនៈ ១២

អាយតនៈខាងក្នុង ៦ និង អាយតនៈ ខាងក្រៅ ៦

## កម្ម ១២

## កម្មឱ្យផលតាមកិច្ច ៤

១. **ជនកកម្ម** កម្មមានកិច្ចជាអ្នកបង្កើត ជាតួនាំសត្វឱ្យកើតក្នុងភពថ្មី ។

២. **ឧបត្ថម្ភកកម្ម** កម្មមានកិច្ចជួយជ្រោមជ្រែងជនកកម្ម

៣. **ឧបបីឡកកម្ម** កម្មមានកិច្ចបៀតបៀនជនកកម្ម

៤. **ឧបឃាតកកម្ម** កម្មមានកិច្ចផ្តាច់បង់នូវជនកកម្ម និងកម្មដទៃ ។

## កម្មឱ្យផលតាមលំដាប់មុនក្រោយ ៤

១. **គរុកម្ម** កម្មមានទម្ងន់ (ឱ្យផលមុនគេ)

២. **អាសន្នកម្ម** កម្មដែលគេធ្វើពេលជិតស្លាប់

៣. **អាចិណ្ណកម្ម(ពហុលកម្ម)** កម្មដែលគេធ្វើរឿយ ៗ

៤. **កដត្តាកម្ម** កម្មដែលគេធ្វើដោយឥតចេតនា ឬ មានចេតនាខ្សោយ ។

## **កម្មឱ្យផលតាមលំដាប់ពេលវេលា ៤**

**១. ទិដ្ឋធម្មវេទនីយកម្ម** កម្មឱ្យផលក្នុងបច្ចុប្បន្ន ។

**២. ឧបបជ្ជវេទនីយកម្ម** កម្មឱ្យផលក្នុងជាតិបន្ទាប់ពីបច្ចុប្បន្ន

**៣. អបរាបរិយវេទនីយកម្ម** កម្មឱ្យផលក្នុងជាតិបន្តទៅមុខទៀត

**៤. អហោសិកម្ម** កម្មលែងឱ្យផល កម្មដែលមិនឱ្យផល។

## **បច្ចយាការ ឬ បដិច្ចសមុប្បាទ ១២**

| | | |
|---|---|---|
| **១. អវិជ្ជា** | ជាបច្ច័យឱ្យកើត | សង្ខារ |
| **២. សង្ខារ** | ជាបច្ច័យឱ្យកើត | វិញ្ញាណ |
| **៣. វិញ្ញាណ** | ជាបច្ច័យឱ្យកើត | នាមរូប |
| **៤. នាមរូប** | ជាបច្ច័យឱ្យកើត | សឡាយតនៈ |
| **៥. សឡាយតនៈ** | ជាបច្ច័យឱ្យកើត | ផស្សៈ |
| **៦. ផស្សៈ** | ជាបច្ច័យឱ្យកើត | វេទនា |
| **៧. វេទនា** | ជាបច្ច័យឱ្យកើត | តណ្ហា |
| **៨. តណ្ហា** | ជាបច្ច័យឱ្យកើត | ឧបាទាន |
| **៩. ឧបាទាន** | ជាបច្ច័យឱ្យកើត | ភព |
| **១០. ភព** | ជាបច្ច័យឱ្យកើត | ជាតិ |

**១១. ជាតិ** ជាបច្ច័យឱ្យកើត ជរា មរណៈ

**១២. ជរា មរណៈ** ជាទីបញ្ចប់នៃជាតិ នីមួយ ៗ ។

## ពួកធម៌ ១៣

## ធុតង្គ ១៣

**១. បង្សុកូលិកង្គៈ** អ្នកទ្រទ្រង់សំពត់បង្សុកូលជាវត្ត

**២. តេចីវរិកង្គៈ** អ្នកទ្រទ្រង់ត្រៃចីវរ (ត្រឹម៣) ជាវត្ត

**៣. បិណ្ឌបាតិកង្គៈ** អ្នកត្រាច់បិណ្ឌបាតជាវត្ត (អត់មានកំណត់)

**៤. សបទានចារិកង្គៈ** អ្នកត្រាច់បិណ្ឌបាតតាមលំដាប់ជាវត្ត ( មានកំណត់ )

**៥. ឯកាសនិកង្គៈ** អ្នកឆាន់ ១ ថ្ងៃតែម្តង

**៦. បត្តបិណ្ឌិកង្គៈ** អ្នកឆាន់តែក្នុងបាត្រ

**៧. ខលុបច្ឆាភត្តិកង្គៈ** អ្នកឆាន់អាហារតាមដែលខ្លួនកំណត់ មិនទទួលអាហារក្រោយពីកំណត់ហើយ

**៨. អារញ្ញិកង្គៈ** អ្នកនៅក្នុងព្រៃជាវត្ត

**៩. រុក្ខមូលិកង្គៈ** អ្នកនៅទៀបគល់ឈើជាវត្ត

**១០. អព្ភោកាសិកង្គៈ** អ្នកនៅក្នុងទីវាលជាវត្ត

**១១. សោសានិកង្គៈ** អ្នកនៅក្នុងព្រៃស្មសានជាវត្ត
**១២.អយថាសន្ថតិកង្គៈ** អ្នកនៅក្នុងសេនាសនៈតាមមានតាមបាន
**១៣. នេសជ្ជិកង្គៈ** អ្នកប្រើឥរិយាបថអង្គុយជាវត្ត ៕

## ចិត្តមាននាទី (កិច្ច) ១៤

| | |
|---|---|
| **១. បដិសន្ធិកិច្ច** | នាទីត ភពជាតិ |
| **២. ភវង្គកិច្ច** | នាទីជាអង្គនៃភព |
| **៣. អាវជ្ជនកិច្ច** | នាទីនឹករកអារម្មណ៍ |
| **៤.ទស្សនកិច្ច** | នាទីឃើញរូប |
| **៥. សវនកិច្ច** | នាទីឮសម្លេង |
| **៦. ឃាយនកិច្ច** | នាទីធុំក្លិន |
| **៧. សាយនកិច្ច** | នាទីដឹងរស |
| **៨.ផុស្សនកិច្ច** | នាទីប៉ះទង្គិច |
| **៩. សម្បដិច្ឆន្នកិច្ច** | នាទីទទួលអារម្មណ៍ |
| **១០. សន្តីរណកិច្ច** | នាទីពិចារណាអារម្មណ៍ |
| **១១. វោដ្ឋព្វនកិច្ច** | នាទីកាត់សេចក្តីអារម្មណ៍ |
| **១២. ជវនកិច្ច** | នាទីសោយអារម្មណ៍ |
| **១៣. តទាលម្ពនកិច្ច** | នាទីទទួលអារម្មណ៍ពីជវនៈ |
| **១៤. ចុតិកិច្ច** | នាទីឃ្លាតចាកភពចាស់ ៕ |

## ចរណៈ ១៥

| | |
|---|---|
| ១. **សីលសំវរៈ** | សង្រួមក្នុងសីល |
| ២. **ឥន្ទ្រិយសំវរៈ** | សង្រួមឥន្ទ្រិយ៍ |
| ៣. **ភោជនេ មត្តញ្ញុតា** | ដឹងប្រមាណក្នុងភោជន |
| ៤. **ជាគរិយានុយោគ** | ប្រកបរឿយ ៗ ក្នុងការភ្ញាក់រឭក |
| ៥. **សទ្ធា** | មានជំនឿត្រឹមត្រូវ |
| ៦. **ហិរិ** | សេចក្ដីខ្មាសបាប |
| ៧. **ឱត្តប្ប** | សេចក្ដីខ្លាចបាប |
| ៨. **ពាហុសច្ច** | ការចេះចាំច្រើន |
| ៩. **វីរិយ** | ( ឧបក្កម )សេចក្ដីព្យាយាម |
| ១០. **សតិ** | សេចក្ដីនឹករឭក |
| ១១. **បញ្ញា** ( **មតិ** ) | សេចក្ដីដឹងច្បាស់ |
| ១២. **បឋមឈាន** | ឈានទី ១ |
| ១៣. **ទុតិយឈាន** | ឈានទី ២ |
| ១៤. **តតិយឈាន** | ឈានទី ៣ |
| ១៥. **ចតុត្ថឈាន** | ឈានទី ៤ ។ |

## **ញាណ ១៦**

**១. នាមរូបបរិច្ឆេទញាណ** ញាណកំណត់ចែក នាម និង រូប

**២. បច្ចយបរិគ្គហញាណ** ញាណកំណត់ដឹងបច្ច័យនៃនាមរូប

**៣. សម្មសនញាណ** ញាណកំណត់ពិចារណា នាម និង រូប ជាព្រះត្រៃលក្ខណ៍ ។

៤. តាំងពីញាណទី ៤ រហូតញាណទី ១២ គឺ វិបស្សនាញាណទាំង ៩ ហ្នឹងឯង ។

**១៣. គោត្រភូញាណ** ញាណឆ្លងចាកគោត្របុថុជ្ជន ទៅកាន់គោត្រអរិយៈ

**១៤. មគ្គញាណ** ញាណក្នុងអរិយមគ្គទាំង ៤

**១៥. ផលញាណ** ញាណក្នុងអរិយផលទាំង ៤

**១៦.បច្ចវេក្ខណញាណ** ញាណពិចារណាពិនិត្យមើលមគ្គផល កិលេសដែលបានលះហើយ កិលេសដែលមិនទាន់បានលះ និង ព្រះនិព្វាន ។

## **ធាតុ ១៨**

**១. ចក្ខុធាតុ** ធាតុ គឺ ចក្ខុ

**២. សោតធាតុ** ធាតុគឺ សោត

**៣. ឃានធាតុ** ធាតុគឺ ឃាន

**៤. ជីវ្ហាធាតុ** ធាតុគឺ ជីវ្ហា

| | |
|---|---|
| **៥. កាយធាតុ** | ធាតុគឺ កាយ |
| **៦. មនោធាតុ** | ធាតុគឺ ចិត្ត |
| **៧. រូបធាតុ** | ធាតុគឺ រូប |
| **៨. សទ្ទធាតុ** | ធាតុគឺ សម្លេង |
| **៩. គន្ធធាតុ** | ធាតុគឺ ក្លិន |
| **១០. រសធាតុ** | ធាតុគឺ រស |
| **១១. ផោដ្ឋព្វធាតុ** | ធាតុគឺ ផោដ្ឋព្វ |
| **១២. ធម្មធាតុ** | ធាតុគឺ ធម៌ ធម្មារម្មណ៍ |
| **១៣. ចក្ខុវិញ្ញាណធាតុ** | ធាតុគឺ ចក្ខុវិញ្ញាណ |
| **១៤. សោតវិញ្ញាណធាតុ** | ធាតុគឺ សោតវិញ្ញាណ |
| **១៥. ឃានវិញ្ញាណធាតុ** | ធាតុគឺ ឃានវិញ្ញាណ |
| **១៦. ជីវ្ហាវិញ្ញាណធាតុ** | ធាតុគឺ ជីវ្ហាវិញ្ញាណ |
| **១៧. កាយវិញ្ញាណធាតុ** | ធាតុគឺ កាយវិញ្ញាណ |
| **១៨. មនោវិញ្ញាណធាតុ** | ធាតុគឺ មនោវិញ្ញាណ ។ |

## ឥន្ទ្រីយ៍ ២២

| | |
|---|---|
| **១. ចក្ខុន្ទ្រីយ** | ឥន្ទ្រីយ៍គឺ ចក្ខុ |
| **២. សោតិន្ទ្រីយ** | ឥន្ទ្រីយ៍គឺ សោត |
| **៣. ឃានិន្ទ្រីយ** | ឥន្ទ្រីយ៍គឺ ឃាន |

៤. **ជិវ្ហិន្ទ្រីយ** ឥន្ទ្រីយ៍គឺ ជីវ្ហា
៥. **កាយិន្ទ្រីយ** ឥន្ទ្រីយ៍គឺ កាយ
៦. **មនិន្ទ្រីយ** ឥន្ទ្រីយ៍គឺ ចិត្ត មនោ
៧. **ឥត្ថិន្ទ្រីយ** ឥន្ទ្រីយ៍គឺ ភាវៈជាស្រ្តី
៨. **បុរិសិន្ទ្រីយ** ឥន្ទ្រីយ៍គឺ ភាវៈជាបុរស
៩. **ជីវិតិន្ទ្រីយ** ឥន្ទ្រីយ៍គឺ ជីវិត
១០. **សុខិន្ទ្រីយ** ឥន្ទ្រីយ៍គឺ សេចក្តីសុខ
១១. **ទុក្ខិន្ទ្រីយ** ឥន្ទ្រីយ៍គឺ សេចក្តីទុក្ខ
១២. **សោមនស្សិន្ទ្រីយ** ឥន្ទ្រីយ៍គឺ សេចក្តីសោមនស្ស
១៣. **ទោមនស្សិន្ទ្រីយ** ឥន្ទ្រីយ៍គឺ សេចក្តីទោមនស្ស
១៤. **ឧបេក្ខិន្ទ្រីយ** ឥន្ទ្រីយ៍គឺ ឧបេក្ខា
១៥. **សទ្ធិន្ទ្រីយ** ឥន្ទ្រីយ៍គឺ សទ្ធា
១៦. **វីរិយិន្ទ្រីយ** ឥន្ទ្រីយ៍គឺ វីរិយ
១៧. **សតិន្ទ្រីយ** ឥន្ទ្រីយ៍គឺ សតិ
១៨. **សមាធិន្ទ្រីយ** ឥន្ទ្រីយ៍គឺ សមាធិ
១៩. **បញ្ញិន្ទ្រីយ** ឥន្ទ្រីយ៍គឺ បញ្ញា
២០. **អនញ្ញាតញ្ញស្សាមិតិន្ទ្រីយ** ឥន្ទ្រីយ៍គឺ សេចក្តីដឹងថា យើងនឹងដឹងធម៌( ព្រះនិព្វាន ) ដែលមិនទាន់បានដឹង (បានដល់សោតាបត្តិមគ្គញាណ )

**២១. អញ្ញិន្ទ្រិយ** ឥន្ទ្រីយ៍គឺ កិរិយាត្រាស់ដឹងនូវធម៌ (បានដល់សោតាបត្តិផលញាណជាដើម អរហត្តមគ្គញាណជាបរិយោសាន)

**២២. អញ្ញាតាវិន្ទ្រិយ** ឥន្ទ្រីយ៍គឺ អរហត្តផល ដែលបុគ្គលដឹងច្បាស់ហើយ ។

**ពោធិបក្ខិយធម៌ ៣៧ គឺ**

| | |
|---|---|
| ១. **សតិប្បដ្ឋាន** | ៤ |
| ២. **សម្មប្បធាន** | ៤ |
| ៣. **ឥទ្ធិបាទ** | ៤ |
| ៤. **ឥន្ទ្រីយ** | ៥ |
| ៥. **ពលៈ** | ៥ |
| ៦. **ពោជ្ឈង្គ** | ៧ |
| ៧. **មគ្គ** ( **អដ្ឋង្គិកមគ្គ** ) | ៨ |

សូមអញ្ជើញមើល តាមធម៌ពួកនោះ ៗ ដែលបានរៀបរៀងទុកក្នុងខាងដើមសព្វគ្រប់អស់ហើយ ។

ខន្ធ ៥, អាយតនៈ ១២, ធាតុ ១៨, ឥន្ទ្រីយ ២២, អរិយសច្ច ៤ , បដិច្ចសមុប្បាទ ១២, រួមគ្នាត្រូវជា ៧៣ ជាអារម្មណ៍របស់វិបស្សនាកម្មដ្ឋាន ។

**ចប់**

# មគ្គមានអង្គ ៨

មគ្គមានអង្គ ៨ ជាវិធីដ៏ប្រសើរ
សម្រាប់ឱ្យយើងដើរ ទៅរកសុខសួគ៌និព្វាន ។
មួយការយល់ឃើញត្រូវ ដែលជាផ្លូវបញ្ញាញាណ
ឃើញក្តីទុក្ខបៀតបៀន ឥតស្រាកស្រាន្ត ១២ កង ។
ឃើញហេតុឱ្យកើតទុក្ខ គឺតណ្ហា ៣ នោះផង
ឃើញសុខក្រៃកន្លង អស់សៅហ្មង គឺ និរោធ ។
ឃើញផ្លូវត្រូវកណ្តាល យ៉ាងត្រកាលមិនគ្រោតគ្រោត
ឱ្យបានដល់សម្ពោធ និងនិព្វានក្សេមក្សាន្តហោង ។
ទីពីរការគិតត្រូវ ដែលជាផ្លូវចាកកាមផង
និងចិត្តគិតប៉ុនប៉ង សងគំនុំគុំព្យាបាទ ។
ចេញចាកវិហឹសា ការបៀតបៀនរលីងស្អាត
មិនមានក្តីប្រមាថ ខំសង្វាតធម៌មេត្តា ។
ទីបីសំដីត្រូវ ដែលជាផ្លូវល្អថ្លៃថ្លា
វៀរចាកពាក្យមុសា ពាក្យញុះញង់ ពាក្យទ្រគោះ ។
រោយរាយឥតប្រយោជន៍ កេរ្តិ៍អសោចមិនពីរោះ
ពាក្យសំដីឡេះឡោះ វៀរទាំងអស់មិនចរចា ។
ទីបួនការងារត្រូវ ដែលជាផ្លូវនៃកាយា

តែងវៀរចាកបាណា អទិន្នា និង កាមេ ។
មិនដែលសម្លាប់សត្វ លួចសម្បត្តិទ្រព្យរបស់គេ
មិនដែលខុសឆ្គងទេ ប្រពៃណីប្ដីប្រពន្ធ ។
ទីប្រាំធ្វើការងារ ជា របរ រកទ្រព្យធន
មិនដែលគេចវេះពន្ធ ក្លែងបន្លំធ្វើខុសច្បាប់ ។
ធ្វើតាមធម៌វិន័យ ព្រះជិនស្រីទ្រង់ប្រញាប្ដ
មិនមែនចង់បានឆាប់ ប្រញាប់យករស់តែឯង ។
ទីប្រាំមួយព្យាយាម ប្រព្រឹត្តតាមដោយប្រឹងប្រែង
បិទបាបគ្រប់កន្លែង មិនឱ្យវាកើតឡើងបាន ។
បាបចាស់ខំលះចេញ មិនឱ្យនៅពេញសន្ដាន
អំពើបុណ្យកល្យាណ សាងឱ្យបានកាន់តែច្រើន ។
ទីប្រាំពីរសតិ រលឹកត្រូវផ្លូវចម្រើន
ក្នុងកាយឱ្យបានច្រើន វេទនា និង ចិត្តផង ។
រលឹកដល់ព្រះធម៌ ដ៏បវរពេញកន្លង
ជាគោលធម៌ចម្បង គឺសតិប្បដ្ឋាន ៤ ។
ទីប្រាំបីសម្មា សមាធិតាំងមាំមួន
ចិត្តស៊ប់ក្នុងឈាន ៤ មានកុសលជាអារម្មណ៍ ។
ធ្វើវិបស្សនា ពិចារណាដោយខិតខំ
ប្រឹងប្រែងគ្មានសន្សំ កម្លាំងកាយ និង ចិត្តឡើយ ។

យូរទៅគង់តែបាន សម្រេចធម៌ជាត្រាណត្រើយ
និព្វាននោះឯងហើយ ជាទីក្សេមចាកទុក្ខភ័យ ។
សាធុជនទាំងឡាយ ចូរខ្វល់ខ្វាយខំលកលៃ
ដើរតាមមគ្គ ៨ រៀងរាល់ថ្ងៃកុំបីខាន ។
អ្នកនឹងបានចម្រើន ស្ងប់ត្រជាក់សុខក្សេមក្សាន្ត
គ្រប់គ្នាពិតពុំខាន គ្រប់ ៗ ប្រាណក្សាន្តភិរម្យ ៕

ចាក ប្រស្នា អដ្ឋង្គិកមគ្គ ឆ្នាំ ១៩៩៤



# លោកអ្នក សប្បុរសដែលបានជួយឧបត្ថម្ភការបោះពុម្ព

| | | |
|---|---|---|
| ១ | ឧបាសិកា អុង ដារី | ១០€ |
| ២ | ឧបាសិកា ប៊ុត សេង គ្រួសារ និង កូនប្រុសស្រី | ១០€ |
| ៣ | ឧបាសិកា ប៊ុន ហ៊ុនគី គ្រួសារ និង កូនចៅ | ១០€ |
| ៤ | ឧបាសិកា តាំង ដាវ៉ាន់ គ្រួសារ និង កូនចៅ | ៥€ |
| ៥ | ឧបាសិកា គិម សូផន  កូនប្រុសស្រី និង ចៅ | ២៥€ |
| ៦ | ឧបាសិកា នៅ ទាវខេង កូនប្រុសស្រី និង ចៅ | ១០€ |
| ៧ | ឧបាសិកា សេក ហេង កូនប្រុសស្រី និង ចៅ | ១០€ |
| ៨ | ឧបាសិកា ឡៃ គីមលៀង កូនប្រុសស្រី និង ចៅ | ១០€ |
| ៩ | ឧបាសិកា សាំង បូ រ៉ែម ព្រមទាំង កូន និង ចៅ | ១០€ |
| ១០ | ឧបាសិកា ហាក់ ព្រួ ព្រមទាំង កូន និង ចៅ | ៣០€ |
| ១១ | ឧបាសិកា កុល សូវ៉ាលី | ១០€ |
| ១២ | ឧបាសិកា កុយ សូរិយា គ្រួសារ កូនប្រុសស្រី និងចៅ | ១០€ |
| ១៣ | លោក ឃិន សូផល ភរិយា និង កូន ប្រុសស្រី | ១០€ |
| ១៤ | លោក ឈឹម សារ៉ាពេជ្រ អ្នកស្រី លឹម ផាន់ (ភរិយា) | ២៥€ |
| ១៥ | M. Lim William | ១០€ |
| ១៦ | ឧបាសិកា ឌី សាម៉ាវ៉ាន់ ( អ្នកកត់ចម្លង ) | ២០€ |
| ១៧ | M. Mme Thong Simon | ១០€ |
| ១៨ | ឧបាសិកា ជិន នារី | ១០€ |
| ១៩ | ឧបាសិកា មាស ឆវី | ១០€ |

| | | |
|---|---|---|
| ២០ | ឧបាសិកា វ៉ាន់ នីន | ១០€ |
| ២១ | ឧបាសិកា ណៃម លិម អ៊ាន ណៃម លិម អ៊ិន | ២០€ |
| ២២ | ឧបាសិកា ទា គឹមលន់ | ១០€ |
| ២៣ | ឧបាសក ឧបាសិកា ជិន ផុង | ១០€ |
| ២៤ | ឧបាសិកា សុខ ហៀក | ១០€ |
| ២៥ | ឧបាសិកា កែ គឹម សួត | ១០€ |
| ២៦ | ឧបាសក ឧបាសិកា ចេត សែម | ១០€ |
| ២៧ | ឧបាសិកា កា នីកូល | ១០€ |
| ២៨ | ឧបាសក ឧបាសិកា អាន តាយ្យគីម | ១០€ |
| ២៩ | ឧបាសិកា ទេព ស៊ុយ អ៊ាង | ១០€ |
| ៣០ | ឧបាសិកា ស៊ាម អ៊ាមជន | ១០€ |
| ៣១ | ឧបាសិកា យូ កែវវណ្ណា | ១០€ |
| ៣២ | ឧបាសិកា គីម ម៉ារី | ១០€ |
| ៣៣ | ឧបាសិកា ទា គឹមលី | ១០€ |
| ៣៤ | ឧបាសិកា ប៉ុន ហ៊ុលឃុត | ៣០€ |
| ៣៥ | ឧបាសិកា ថ្លាង អាង | ១០€ |
| ៣៦ | ឧបាសិកា ជិន នារី | ១០€ |
| ៣៧ | ឧបាសក ឧបាសិកា ប្រុក មនោ និង កូនចៅ | ៥០€ |
| ៣៨ | ឧបាសិកា តេង អ៊ានឆឹង និង កូនចៅ | ៣០€ |
| ៣៩ | ឧបាសិកា សួស សុភា | ១០€ |
| ៤០ | អ្នកស្រី សួស សូភា និង គ្រួសារ និង កូន ប្រុសស្រី | ១០€ |

| | | |
|---|---|---|
| ៤១ | លោក ហេង គីម និង ភរិយា ព្រមទាំងកូនចៅ | ៥០€ |
| ៤២ | អាចារ្យ មិន ធូ ឧបាសិកា តាំង វួច ប៉ោ | ៥០€ |
| ៤៣ | លោក ង្វី ហុក និង ភរិយា | ៥០€ |
| ៤៤ | ឧបាសក ខេង នៅ ឧបាសិកា តែ ចាយ | ៥០€ |
| ៤៥ | ឧបាសិកា គុល ទូច | ៥០€ |
| ៤៦ | អ្នកស្រី គីម មួយ | ៥០€ |
| ៤៧ | ឧបាសក ឧបាសិកា អ៊ិន សារេន | ៥០€ |
| ៤៨ | ឧបាសិកា ផាត់ ឡាយ | ៥០€ |
| ៤៩ | In Dana, In Dano, In Danea, In Mada | ៤០€ |
| ៥០ | Mm In Daravy | ១០€ |
| ៥១ | កុមារា កុសុន, កុមារី Alanis , កុមារី Léona | ១៥€ |

យើងខ្ញុំ សូមឧទ្ទិសចំណែកបុណ្យនេះ ប្រគេន ជូន វិញ្ញាណក្ខន្ធ លោកអ្នកដ៏មានគុណទាំងឡាយ មានគ្រូឧបជ្ឈាយាចារ្យ និង មាតាបិតាជាដើមផងព្រមទាំងញាតិមិត្រ ទាំងឡាយផង។សូមលោកអ្នកដ៏មានគុណជាដើមនោះ អនុមោទនាទទួលយកនូវ ឥដ្ឋមនុញ្ញផលជាទីគាប់ចិត្ត តាមសេចក្តីជ្រះថ្លារៀង ៗ ខ្លួន កុំបីខាន៕

# ឧបេក្ខាចិត្ត

តាំងចិត្តនឹងមាំស្ងប់ កុំឱ្យស្អប់កុំស្រឡាញ់
ឧបេក្ខាចិត្តវិញ មានសតិ សម្បជញ្ញៈ ។
ឃើញរូបឮសម្លេង មិនវង្វេងជាប់ជំពាក់
ក្លិន រស ផោដ្ឋព្វៈ និង ធម្មៈ កើតក្នុងចិត្ត ។
ទោះបី ខ្មៅ ឬ ស អាក្រក់ ល្អ ដ៏ប្រណីត
មិនអាចអូសទាញចិត្ត ឱ្យស្រឡាញ់ ឬ ស្អប់ឡើយ ។
អ្នកធ្វើយ៉ាងនេះបាន ឃើញធម៌ច្បាស់ប្រាកដហើយ
ដល់ទីពឹងត្រាណត្រើយ សុខឥតស្មើយនិព្វានហោង ។

**ភិក្ខុ ខិន គេន ឥន្ទប្បញ្ញោ**

# ពុទ្ធបរិស័ទត្រូវដឹង

លោកអ្នកពុទ្ធបរិស័ទ ដែលបដិបត្តិតាមសាសនា
ត្រូវមានសទ្ធា និង បញ្ញា ទាំងពីរប្រការនេះកុំខាន ។
ដើម្បីនាំ និង បំភ្លឺផ្លូវ ឱ្យបានដល់ទៅទីថ្កើងថ្កាន
ទីរំលត់ទុក្ខ គឺ និព្វាន ស្ងប់សុខក្សេមក្សាន្តក្រៃកន្លង ។
ត្រូវឧបត្ថម្ភពុទ្ធសាសនា ទុកជាភេត្រាជួយចម្លង
ឱ្យពួកអ្នកក្រោយគេបានឆ្លង ដល់និព្វានផង កុំបីខាន ។

**ភិក្ខុ ខិន តេន ឥន្ទប្បញ្ញោ**

# មិនមានអញ ក្នុងខន្ធប្រាំ

យើងសំគាល់រូបថារូបអញ		វេទនា សញ្ញា អញដែរ
សង្ខារវិញ្ញាណអញហូរហែ		អ្វីៗ អញដែរ អញទាំងអស់ ។
បើវែកញែកមើលនៅក្នុងខ្លួន		មិនឃើញមានអ្វីជាអញសោះ
ឃើញដីទឹកភ្លើងខ្យល់ប៉ុណ្ណោះ		មិនឃើញអញសោះនៅត្រង់ណា។
វេទនាដឹងសោយសុខទុក្ខ		គ្រប់មុខរាល់រូបរាល់អាត្មា
ផ្សំគ្នាកើតឡើងតាមហេតុការណ៍		គ្មានអញអត្តាត្រង់ណាសោះ ។
ចំណែក សញ្ញា កត់ចំណាំ		ចាំរូបសម្លេង ទាប និង ខ្ពស់
ខ្មៅ ស វែង ខ្លីអ្វីទាំងអស់		ក្នុងនោះក៏គ្មានអត្តាដែរ ។
សង្ខារតាក់តែងផ្សំផ្គុំគិត		កើតជាគំនិតច្រើនឥតល្ហែ
បាបបុណ្យគុណទោសរាល់ថ្ងៃខែ		ក្នុងនោះក៏ដែរគ្មានអញទៀត ។
វិញ្ញាណឃើញរូបឮសម្លេង		ធុំក្លិនផ្សេងៗ ភ្លក់រសជាតិ
រឹងទន់ត្រជាក់ក្តៅប៉ះបៀត		ក្នុងនោះក៏ទៀតគ្មានអញឡើយ ។
យើងជឿប្រកាន់ស្មានតាមគ្នា		អស់ពេលវេលាមកយូរហើយ
កើតទុក្ខតានតឹងចិត្តឥតស្បើយ		អ្នកកើយឈប់ជឿខុសទៀតទៅ។

Vatt Bodhivansa (A. S. B. K.)
101 Bd.de la République
77420 Champs-sur-Marne

Tél. 01 60 06 44 98
01 64 62 17 41

Site : vatt. Bodhivansa.free.fr